**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ១៣០/២០ សណ.ក

# សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

**កម្មវត្ថុ:** សូមគោរពអនុញ្ញាតផ្ញើសេចក្តីរាយការណ៍អំពីលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពី " កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)។

**យោង** ៖ លិខិតលេខ ០១៨/២០ សណ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០២០ និងចំណារដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២០ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពរាយការណ៍ជូន**សម្តេចក្រឡាហោម** មេត្តាជ្រាបថា៖ បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី សម្តេចក្រឡាហោម កាលពីថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) រួមសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានរៀបចំសិក្ខាសាលា " **ពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់**( Global Compact for safe, Orderly and regular Migration : GCM )"ក្នុងគោលបំណងប្រមូលធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាលកម្ពុជា អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងអង្គការដៃគូអភិវឌ្ឍន៍ ដើម្បីជ្រើសរើសគោលបំណងអាទិភាពចំនួន ០២ ឬ ០៣ លើគោលបំណងទាំង ២៣ ដែលកំណត់ក្នុងកតិកាសញ្ញា មកអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា *(គោរពជូនភ្ជាប់នូវឯកសារ គោលបំណងទាំង ២៣ របស់ GCM ចំនួន ០១ ច្បាប់)* ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកអង្គសិក្ខាសាលា ។

កម្មវិធីនៃអង្គសិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន ពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងអង្គការដៃគូអភិវឌ្ឍន៍ប្រមាណ ១៧០ នាក់ ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើកិច្ចពិគ្រោះយោបល់កម្រិតជំនាញថ្នាក់ជាតិ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានកិច្ចសហការរវាងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលមានសមាសភាពជាមន្ត្រីជំនាញរបស់ ក្រុមការងារអន្តរក្រសួងស្ថាប័នទាំង ០៦របស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) រួមមាន ក្រសួងអប់រំ យុវជន និងកីឡា អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងពាក់ព័ន្ធ ព្រមទាំងអ្នកជំនាញ ពីអង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ។ ក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់បច្ចេកទេសនេះ បានពិភាក្សាគ្នាយ៉ាងផុលផុស ជ្រើសរើសបានគោលបំណងចំនួន ០៣ជាអាទិភាព និងគោលបំណងត្រៀមចំនួន ០៤ ពីក្នុងគោលបំណងទាំង ២៣ របស់កតិកាសញ្ញា ដើម្បីដាក់ជូនកិច្ចប្រជុំកម្រិតខ្ពស់ធ្វើការសម្រេចចុងក្រោយ ។

ដើម្បីជូនជ្រាបអំពីសារតានៃកតិកាសញ្ញានេះ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា មុននឹងឈានដល់សិក្ខាសាលាថ្ងៃនេះ ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្ត ចូលរួមក្នុងដំណើរការនៃការរៀបចំ និងអនុម័តកតិកាសញ្ញានេះ ដោយបានឆ្លងកាត់ដំណាក់កាលជាបន្តបន្ទាប់ទាំងនៅក្នុងប្រទេស និងអន្តរជាតិ ចំនួន ០៥លើក រួចមកហើយ គិតចាប់ពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ដល់ ទី ១០-១១ ខែធ្នូ ឆ្នាំ ២០១៨ ដើម្បីជាប្រយោជន៍ក្នុងការដោះស្រាយ និងគ្រប់គ្រងបញ្ហាទេសន្តរប្រវេសន៍ ដែលកម្ពុជាបាន និងកំពុងតែប្រឈម ឱ្យបានប្រសើរឡើងនៅក្នុងកិច្ចសហការជាអន្តរជាតិ តាមគ្រប់ទិដ្ឋភាព ដើម្បីជាប្រយោជន៍រួមគ្នាសម្រាប់ប្រទេសនានាក្នុងពិភពលោក។

-កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានទទួលការអនុញ្ញាតជាគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល និងដោយមានកិច្ចសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) រៀបចំការពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី «ការចូលរួមក្នុងដំណើរការ រៀបចំកតិកាសញ្ញាពិភពលោក» ដោយសិក្សាអំពីបញ្ហាប្រឈមនៅថ្នាក់ជាតិពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ដើម្បីឈានទៅការដាក់បញ្ចូលជាដំណោះស្រាយរួមគ្នា។ ការពិគ្រោះយោបល់នេះ ត្រូវបានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួម ១៧០នាក់ មកពីស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល អង្គការដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន និងទទួលបានការផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ពី**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

- នៅថ្ងៃទី ៦-៨ ខែវិច្ឆិកា ឆ្នាំ២០១៧ រាជរដ្ឋាភិបាល បានចាត់បញ្ជូននាងខ្ញុំ ដែលជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឲ្យដឹកនាំគណៈប្រតិភូចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីត្រៀមរៀបចំកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅទីក្រុងបាងកក រៀបចំដោយអង្គការ UNESCAP, IOM, ILO, UNDP, UNFPA, UNHCR, UN WOMEN និង UNODC ដើម្បីពិនិត្យវាយតម្លៃផលប៉ះពាល់នៃទេសន្តរប្រវេសន៍ លើវិស័យសង្គម និងសេដ្ឋកិច្ច ។

- នៅថ្ងៃទី ៤-៦ ខែធ្នូ ឆ្នាំ២០១៧ នាងខ្ញុំបានទទួលការអនុញ្ញាតជាថ្មី ទៅចូលរួមសន្និសីទអន្តរជាតិ ស្តីពីកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលសន្និសីទអន្តរជាតិ នាទីក្រុង Puerto Vallarta, ប្រទេសម៉ិកស៊ិច ដើម្បីពិភាក្សារៀបចំខ្លឹមសារដាក់បញ្ចូលក្នុងសេចក្តីព្រាងបឋម នៃកតិកាសញ្ញា ។

- នៅថ្ងៃទី ២០-២៣ ខែកុម្ភៈ ឆ្នាំ២០១៨ នាងខ្ញុំ បានទៅចូលរួមបន្តក្នុងកិច្ចប្រជុំបច្ចេកទេស ពីតំណាងប្រទេសក្នុងពិភពលោក ដើម្បីពិភាក្សាបន្ថែមលើសេចក្តីព្រាងខ្លឹមសារកតិកាសញ្ញា រៀបចំដោយតំណាងពិសេស ( Special Representatives of the Secretary General: SRSG ) នៃអគ្គលេខាធិការដ្ឋានសម្រាប់ទេសន្តរប្រវេសន៍អន្តរជាតិ និងរៀបចំនីតិវិធី នាទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

- និងជាចុងក្រោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានចាត់តាំងនាងខ្ញុំ ជាតំណាង ដើម្បីចូលរួមអនុម័តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ( GCM ) ដែលប្រព្រឹត្តទៅនាទីក្រុង ម៉ារ៉ាកិច ប្រទេស ម៉ារ៉ុក នាថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៨ ។

ការអនុម័តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយ សុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅខែធ្នូ ឆ្នាំ២០១៨ គឺជាសមិទ្ធិផលដ៏ល្អមួយ ហើយជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ នៃអង្គការសហប្រជាជាតិ ដែលរដ្ឋសមាជិកបានរួមសាមគ្គី និងឯកភាពគ្នា ប្តេជ្ញាចិត្ត លើកកម្ពស់កិច្ចសហប្រតិបត្តិការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍អន្តរជាតិ ដើម្បីទទួលបានផលប្រយោជន៍ជាអតិបរមា ក្នុងពេលដោះស្រាយបញ្ហា និងបញ្ហាប្រឈមរបស់ខ្លួន ។ កតិកាសញ្ញានេះជាឱកាសមួយសម្រាប់អនុវត្តការងារបន្ត ទាក់ទងនឹងបញ្ហាសំខាន់ៗនៃទេសន្តរប្រវេសន៍ ដែលមាននៅក្នុងរបៀបវារៈឆ្នាំ២០៣០ នៃការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងធានាថា ជនទេសន្តរប្រវេសន៍នឹងមិនត្រូវបានបោះបង់ចោលទេ។ កតិកាសញ្ញាផ្តល់ឱ្យជាពិសេស នូវឱកាសពិតដល់រដ្ឋសមាជិក ដើម្បីបញ្ជាក់ច្បាស់សារជាថ្មី នូវការអនុវត្តការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់ និងកំណត់ក្រិតក្រម ពាក់ព័ន្ធក្នុងគោលនយោបាយទេសន្តរប្រវេសន៍អន្តរជាតិ ដោយដោះស្រាយកង្វះចន្លោះមួយចំនួននៅក្នុងកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។

**គោលបំណងជាអាទិភាពចំនួន ០២ ដែលជាការជ្រើសរើសរបស់អង្គសិក្ខាសាលាថ្នាក់ជាតិ គឺ៖**

**គោលបំណងទី១ ៖** ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមភេទជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង។

**គោលបំណងទី២ ៖** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។

*ចំពោះគោលបំណងជាអាទិភាពបម្រុង ចំនួន១ គឺ៖*

**គោលបំណងជាអាទិភាពបម្រុង៖** គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា ។

អង្គសិក្ខាសាលាថ្នាក់ជាតិ កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាលនេះ បានទទួលស្គាល់ថាគោលបំណងដែលបានជ្រើសរើសខាងលើនេះ ពិតជាមានសារសំខាន់ជាមូលដ្ឋានសម្រាប់ការអនុវត្តគោល

បំណាងដទៃទៀត ហើយអាចធ្វើឲ្យសម្រេចបាន សក្តិសមនឹងពេលវេលាកំណត់ ដែលប្រមុខរដ្ឋាភិបាល នៃបណ្តារដ្ឋជាសមាជិក ត្រូវរាយការណ៍អំពីលទ្ធផលជូនអង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០២២ ។

ក្នុងឆ្នាំ ២០២២ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាបណ្តារដ្ឋជាសមាជិក នៃកតិកាសញ្ញា (Global Compact Migration(GCM)) នឹងត្រូវធ្វើរបាយការណ៍អំពីស្ថានភាពនៃការអនុវត្តគោលបំណងដែលបានជ្រើសរើស នៅមហាសន្និបាតអង្គការសហប្រជាជាតិ នាទីក្រុង ញូវយ៉ក ដែលប្រារព្ធធ្វើរៀងរាល់ ០៤ ឆ្នាំ ម្តង។

ផ្អែកតាមលទ្ធផល នៃអង្គសិក្ខាសាលាកម្រិតថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដែលបានអនុម័ត នឹងដើម្បីមានមូលដ្ឋានសម្រាប់ប្រមុខរាជរដ្ឋាភិបាលធ្វើសេចក្តីរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំ ២០២២ តាមការគ្រោងទុក នាងខ្ញុំសូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ដើម្បីរៀបចំរបាយការណ៍គោរពរាយការណ៍ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អំពីលទ្ធផលនៃអង្គសិក្ខាសាលា នឹងគោរពស្នើសុំគោលការណ៍ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីស្នើក្រសួង-ស្ថាប័ន ពាក់ព័ន្ធរៀបចំផែនការអនុវត្ត ឈានទៅសម្រេចបាននូវគោលបំណង ចំនួន ០២ ដែលបានជ្រើសរើសរួមគ្នាសម្រាប់កម្ពុជា ។ របាយការណ៍នេះ នឹងត្រូវប្រមូលចងក្រងដោយ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើសូម **សម្តេចក្រឡាហោម** មេត្តាពិនិត្យសម្រេច និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ថ្ងៃសុក្រ ១០ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០១៨/......

## សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូលលេខ: ២៥៥
ថ្ងៃទី......ម៉ោង
ហត្ថលេខា:......

**កម្មវត្ថុ:** សំណើសុំគោលការណ៍អនុញ្ញាតដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ដើម្បីធ្វើការពិភាក្សាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការជ្រើសរើសវិស័យអាទិភាពសំខាន់ៗ និងគោលដៅជាអាទិភាពដែលត្រូវអនុវត្តពីក្នុងគោលដៅទាំង២៣ របស់ GCM នៅអំឡុងចុងខែ មីនា ឆ្នាំ ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា ៖ អង្គការ Global Compact For Migration (GCM) ត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៨ នៅទីក្រុងញូយ៉ក (New York) សហរដ្ឋអាមេរិក ដែលមានប្រទេសចំនួន១៥២ ជាសមាជិក ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរជាសមាជិក។ កាលពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដែលជាតំណាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងដោយមានកិច្ចសហការសម្របសម្រួលជាមួយអង្គការ IOM <u>បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើកដំបូងនៅរាជធានីភ្នំពេញ</u> ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា **ប្រធាន គ.ជ.ប.ជ** ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាលពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចំនួន ១៧០តំណាង ដើម្បីរៀបចំសម្រាប់ការអនុម័តសកម្មភាពជាគោលដៅរបស់ GCM នៅថ្ងៃទី ១០-១១ ខែ ធ្នូ ឆ្នាំ ២០១៨ នៅទីក្រុងម៉ារ៉ាកេស (Marrakeh) នៃប្រទេសម៉ារុក។

អំឡុងនៃកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកដំបូង បញ្ហាជាគន្លឹះជារួមគឺ <u>ការធ្វើចំណាកស្រុកមិនប្រក្រតី ព្រោះវាបង្ហាញពីភាពងាយរងគ្រោះខ្ពស់ និងនៅតែជានិន្នាការទូទៅក្នុងចំណោមជនចំណាកស្រុកកម្ពុជាជាពលករ។ បញ្ហាបន្ថែមដែលត្រូវបានកំណត់គឺការធ្វើចំណាកស្រុក និងការគ្រប់គ្រងចំណាកស្រុកដែលជាវិស័យអាទិភាពចម្បងដែលត្រូវដោះស្រាយដើម្បីលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រៀបរយ និងទៀងទាត់។</u>

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៤៤ / គ.ជ.ប.ជ
/២០

សូមគោរពជូន
សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល លេខៈ 762
ថ្ងៃ 17.03.2020
ហត្ថលេខា:.........

**កម្មវត្ថុៈ** គោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពន្យាពេលរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី០២ ដើម្បីកំណត់ជ្រើសរើសគោលបំណងចំនួន ០៣ ពីក្នុងគោលដៅទាំង២៣ របស់ Global Compact for Migration (GCM) ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២០ ទៅប្រារព្ធធ្វើនៅអំឡុងខែ មិថុនា ឆ្នាំ ២០២០ វិញ។

**យោងៈ** - លិខិតលេខ 2020/066/IOM ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០ របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)
- ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា អាស្រ័យដោយស្ថានភាពនៃការឆ្លងរីករាលដាលជំងឺកូវីដ១៩ (Covid-19) កាន់តែធំឡើងៗជាសកល អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) បានស្នើសុំពន្យាពេលរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើក ទី០២ ដើម្បីកំណត់ជ្រើសរើសគោលបំណងចំនួន ០៣ ពីក្នុងគោលដៅទាំង២៣ របស់ Global Compact for Migration (GCM) ដែលគ្រោងនឹងប្រារព្ធធ្វើនាថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២០ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធាន គ.ជ.ប.ជ** ទៅប្រារព្ធធ្វើនៅអំឡុងខែ មិថុនា ឆ្នាំ២០២០ វិញ។ ម្យ៉ាងទៀត ផ្អែកតាមលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក៏បានដាក់បម្រាមមិនអោយចូល និងមិនផ្តល់ទិដ្ឋាការដល់ជនបរទេសមកពីប្រទេសចំនួន០៥ ចូលមកកម្ពុជាផងដែរ ដែលកិច្ចប្រជុំនេះនឹងមានតំណាងអន្តរជាតិរបស់អង្គការសហប្រជាជាតិចូលរួមដែរ។

ផ្អែកតាមស្ថានការណ៍នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ដើម្បីពន្យាពេលនៃការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នេះ ទៅប្រារព្ធធ្វើតាមកាលបរិច្ឆេទខាងលើវិញ ដោយសេចក្តីអនុគ្រោះបំផុត។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម** មេត្តាពិនិត្យ សម្រេច និង ស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃ ច ៥ ៨ ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ០៣ ឆ្នាំ ២០២០

គ. អគ្គលេខាធិការ

ជូ ប៊ុនអេង

ចំណារ៖ ...
១៨/០៣/២០

IOM International Organization for Migration
OIM Organisation Internationale pour les Migrations
OIM Organización Internacional para las Migraciones

Her Excellency Chou Bun Eng
Secretary of State, Ministry of Interior
Permanent Vice Chair, NCCT
Royal Government of Cambodia

Ref No.: 2020/066/IOM

Phnom Penh, 13 March 2020

***Subject:*** ***Postponement of the National Consultation on the Role of the Government and Stakeholders in the Implementation of the Global Compact for Migration***

Your Excellency,

The International Organization for Migration (IOM) Cambodia presents its compliments and sincere appreciation to the Royal Government of Cambodia (RGC) and the National Committee for Counter Trafficking (NCCT) for the cooperation and support to IOM.

In reference to the IOM letter numbered 19/236/IOM dated 27 November 2019, I regret to inform Your Excellency that IOM would like to propose postponement of the **National Consultation on the Role of the Government and Stakeholders in the Implementation of the Global Compact for Migration** to June 2020 due to delay in the budget approval amidst the on-going global COVID-19 situation.

IOM sincerely apologize for any inconvenience associated with the postponement of this national event now.

Should you have any questions or require any further information, please contact the IOM Government Liaison Officer, Mr. Phiev Khay, at 012 966 123 or kphiev@iom.int .

Please accept, Your Excellency, the assurance of my highest consideration.

Sincerely,

INTERNATIONAL ORGANIZATION FOR MIGRATION IOM CAMBODIA

Kristin PARCO
Chief of Mission
IOM Mission in Cambodia

**Mission in Cambodia:**
Tai Ming Group Building, 4th Floor, No.281, Norodom Blvd, Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia, P.O. Box 435
Tel: + 855.23.216532 • Fax: + 855.23.216423 • E-mail : iomphnompenh@iom.int • Internet: http://www.iom.int

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សូមអនុញ្ញាតធ្វើសេចក្តីរាយការណ៍ អំពីលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី២ ស្តីពី " កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ ។

**យោង ៖**
- លិខិតចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៨ របស់លោក **អាន់តូនីញ៉ូ ហ្គូថេរេស** (Anto'nio Guterres) អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ
- លិខិតចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅរាជធានីភ្នំពេញ
- លិខិតសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចាត់តាំង លោកជំទាវ ជូ ប៊ុនអេង ជាតំណាងកម្ពុជាចូលរួមសន្និសីទ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន**សម្តេចអគ្គមហាសេនាបតតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) មានរៀបចំសិក្ខាសាលា " **ពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់**" (Global Compact for safe, orderly and regular Migration : GCM) ក្នុងគោលបំណងប្រមូលធាតុចូល ពីក្រសួង ស្ថាប័ន ពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងអង្គការដៃគូអភិវឌ្ឍន៍ ដើម្បីជ្រើសរើសគោលបំណងអាទិភាពចំនួន ០២ ឬ ០៣ លើគោលបំណងទាំង ២៣ ដែលកំណត់ក្នុងកតិកាសញ្ញា មកអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា *(គោរពជូនភ្ជាប់នូវឯកសារ គោលបំណងទាំង ២៣ របស់ GCM ចំនួន ០១ ច្បាប់)*។

កម្មវិធីនៃអង្គសិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងអង្គការដៃគូអភិវឌ្ឍន៍ ប្រមាណ ១៧០ នាក់ ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើកិច្ចពិគ្រោះយោបល់កម្រិតជំនាញថ្នាក់ជាតិ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២០ ដោយមានកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលមានសមាសភាពជាមន្ត្រីជំនាញរបស់ក្រុមការងារអន្តរក្រសួងស្ថាប័នទាំង០៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស( គ.ជ.ប.ជ ) រួមមាន ក្រសួងអប់រំ យុវជន និងកីឡា

អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងពាក់ព័ន្ធ ព្រមទាំង អ្នកជំនាញ ពីអង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ។ ក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់បច្ចេកទេសនេះ បានពិភាក្សាគ្នាយ៉ាងផុលផុស ជ្រើសរើសបានគោលបំណងចំនួន ០៣ ជាអាទិភាព និងគោលបំណងត្រៀមចំនួន ០៤ ពីក្នុងគោលបំណងទាំង ២៣ របស់កតិកាសញ្ញា ដើម្បីដាក់ជូនកិច្ចប្រជុំកម្រិតខ្ពស់ធ្វើការសម្រេចចុងក្រោយ ។

ដើម្បីជូនជ្រាបអំពីសាវតានៃកតិកាសញ្ញានេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា មុននឹងឈានដល់សិក្ខាសាលាថ្ងៃនេះ ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្ត ចូលរួមក្នុងដំណើរការនៃការរៀបចំ និងអនុម័តកតិកាសញ្ញានេះ ដោយបានឆ្លងកាត់ដំណាក់កាលជាបន្តបន្ទាប់ទាំងនៅក្នុងប្រទេស និងអន្តរជាតិ ចំនួន ០៥លើក រួចមកហើយ គិតចាប់ពីថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧ ដល់ ទី ១០-១១ ខែធ្នូ ឆ្នាំ២០១៨ ដើម្បីជាប្រយោជន៍ក្នុងការដោះស្រាយ និងគ្រប់គ្រងបញ្ហាទេសន្តរប្រវេសន៍ដែលកម្ពុជាបាន និងកំពុងតែប្រឈម ឱ្យបានប្រសើរឡើងនៅក្នុងកិច្ចសហការជាអន្តរជាតិ តាមគ្រប់ទិដ្ឋភាព ដើម្បីជាប្រយោជន៍រួមគ្នាសម្រាប់ប្រទេសនានាក្នុងពិភពលោក។

- **កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧** អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានទទួលការអនុញ្ញាតជាគោលការណ៍ ពីប្រមុខរាជរដ្ឋាភិបាល និងដោយមានកិច្ចសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) រៀបចំការពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី «ការចូលរួមក្នុងដំណើរការ រៀបចំកតិកាសញ្ញាពិភពលោក» ដោយសិក្សាអំពីបញ្ហាប្រឈមនៅថ្នាក់ជាតិ ពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ដើម្បីឈានទៅការដាក់បញ្ចូលជាដំណោះស្រាយរួមគ្នា ។ ការពិគ្រោះយោបល់នេះ ត្រូវបានប្រារព្ធធ្វើឡើង នៅរាជធានីភ្នំពេញ ដោយខ្ញុំបានដឹកនាំការពិគ្រោះយោបល់នេះ និងក្នុងនាមជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដែលមានអ្នកចូលរួម ១៧០នាក់ មកពីស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល អង្គការដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។
- **នៅថ្ងៃទី ៦-៨ ខែវិច្ឆិកា ឆ្នាំ២០១៧** រាជរដ្ឋាភិបាល បានចាត់បញ្ជូន **លោកជំទាវ ជូ ប៊ុនអេង** ដែលជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឲ្យដឹកនាំគណៈប្រតិភូចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីត្រៀមរៀបចំកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅទីក្រុងបាងកក រៀបចំដោយអង្គការ UNESCAP, IOM, ILO, UNDP, UNFPA, UNHCR, UN WOMEN និង UNODC ដើម្បីពិនិត្យវាយតម្លៃផលប៉ះពាល់នៃទេសន្តរប្រវេសន៍ លើវិស័យសង្គម និងសេដ្ឋកិច្ច ។
- **នៅថ្ងៃ ទី ៤-៦ ខែធ្នូ ឆ្នាំ២០១៧ លោកជំទាវ ជូ ប៊ុនអេង** បានទទួលការអនុញ្ញាតជាថ្មី ទៅចូលរួមសន្និសីទអន្តរជាតិ ស្តីពី កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលសន្និសីទអន្តរជាតិ នាទីក្រុង Puerto Vallarta, ប្រទេសម៉ិកស៊ិច ដើម្បីពិភាក្សារៀបចំខ្លឹមសារ ដាក់បញ្ចូលក្នុងសេចក្តីព្រាងបឋម នៃកតិកាសញ្ញា ។
- **នៅថ្ងៃទី ២០-២៣ ខែកុម្ភៈ ឆ្នាំ២០១៨ លោកជំទាវ ជូ ប៊ុនអេង** បានទៅចូលរួមបន្តក្នុងកិច្ចប្រជុំបច្ចេកទេសពីតំណាងប្រទេសក្នុងពិភពលោក ដើម្បីពិភាក្សាបន្ថែមលើសេចក្តីព្រាងខ្លឹមសារកតិកាសញ្ញា រៀបចំដោយតំណាងពិសេស (Special Representatives of the

Secretary General: SRSG) នៃអគ្គលេខាធិការដ្ឋានសម្រាប់ទេសន្តរប្រវេសន៍អន្តរជាតិ និងរៀបចំនីតិវិធី នាទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

- និងជាចុងក្រោយ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានចាត់តាំង លោកជំទាវ ជូ ប៊ុនអេង ជាតំណាង ដើម្បីចូលរួមអនុម័ត កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ( GCM ) ដែលប្រព្រឹត្តទៅ នាទីក្រុង ម៉ារ៉ាកិច ប្រទេស ម៉ារ៉ុក នាថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៨។

ការអនុម័តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយ សុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅខែធ្នូ ឆ្នាំ ២០១៨ គឺជាសមិទ្ធិផលដ៏ល្អមួយ ហើយជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៃអង្គការសហប្រជាជាតិ ដែលរដ្ឋសមាជិកបានរួមសាមគ្គី និងឯកភាពគ្នា ប្តេជ្ញាចិត្ត លើកកម្ពស់កិច្ចសហប្រតិបត្តិការដោះស្រាយ បញ្ហាទេសន្តរប្រវេសន៍អន្តរជាតិ ដើម្បីទទួលបានផលប្រយោជន៍ជាអតិបរមា ក្នុងពេលដោះស្រាយបញ្ហា និងបញ្ហាប្រឈមរបស់ខ្លួន ។ កតិកាសញ្ញានេះជាឱកាសមួយសម្រាប់អនុវត្តការងារបន្តទាក់ទងនឹងបញ្ហាសំខាន់ៗនៃទេសន្តរប្រវេសន៍ ដែលមាននៅក្នុងរបៀបវារៈឆ្នាំ២០៣០ នៃការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងធានាថា ជនទេសន្តរប្រវេសន៍នឹងមិនត្រូវបានបោះបង់ចោលទេ។ កតិកាសញ្ញាផ្តល់ឱ្យជាពិសេស នូវឱកាសពិតដល់រដ្ឋសមាជិក ដើម្បីបញ្ជាក់ច្បាស់សារជាថ្មី នូវការអនុវត្តការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់ និងកំណត់ក្រឹត្យក្រម ពាក់ព័ន្ធក្នុងគោលនយោបាយទេសន្តរប្រវេសន៍អន្តរជាតិ ដោយដោះស្រាយបញ្ហាខ្វះចន្លោះមួយចំនួននៅក្នុងកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។

គោលបំណងជាអាទិភាពចំនួន ០២ ដែលជាការជ្រើសរើសរបស់អង្គសិក្ខាសាលាថ្នាក់ជាតិ គឺះ

**គោលបំណងទី១** ៖ ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមភេទជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង។

**គោលបំណងទី២** ៖ ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។

*ចំពោះគោលបំណងជាអាទិភាពបម្រុង ចំនួន១ គឺះ*

**គោលបំណងជាអាទិភាពបម្រុងះ** គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា ។

អង្គសិក្ខាសាលាថ្នាក់ជាតិ កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាលនេះ បានទទួលស្គាល់ថាគោលបំណងដែលបានជ្រើសរើសខាងលើនេះ ពិតជាមានសារសំខាន់ជាមូលដ្ឋានសម្រាប់ការអនុវត្តគោលបំណងដទៃទៀត ហើយអាចធ្វើឱ្យសម្រេចបាន សក្តិសមនឹងពេលវេលាកំណត់ ដែលប្រមុខរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិក ត្រូវរាយការណ៍អំពីលទ្ធផលជូនអង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០២២ ។

ក្នុងឆ្នាំ ២០២២ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាបណ្តារដ្ឋជាសមាជិក នៃកតិកាសញ្ញា ( Global Compact Migration( GCM ) ) នឹងត្រូវធ្វើរបាយការណ៍អំពីស្ថានភាពនៃការអនុវត្តគោលបំណងដែលបានជ្រើសរើស នៅមហាសន្និបាតអង្គការសហប្រជាជាតិ នាទីក្រុង ញូវយ៉ក ដែលប្រារព្ធធ្វើរៀងរាល់ ០៤ ឆ្នាំ ម្តង ។

ផ្អែកតាមលទ្ធផល នៃអង្គសិក្ខាសាលាកម្រិតថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដែលបាន អនុម័ត នឹងដើម្បីមានមូលដ្ឋានសម្រាប់ប្រមុខរាជរដ្ឋាភិបាលធ្វើសេចក្តីរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំ២០២២ តាមការគ្រោងទុក ខ្ញុំសូមគោរពស្នើសុំគោលការណ៍ពី **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្ត កតិកាសញ្ញា ដោយសហការជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ដើម្បីរៀបចំផែនការអនុវត្ត ឈានទៅសម្រេចគោលបំណងដែលបានជ្រើសរើសរួមគ្នាសម្រាប់កម្ពុជា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ។

សូម**សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

អគ្គលេខាធិការអ.ស.ប.

ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៨

**សម្តេចតេជោនាយករដ្ឋមន្ត្រី**

ខ្ញុំមានកិត្តិយសសូមអញ្ជើញ**សម្តេចតេជោនាយករដ្ឋមន្ត្រី**ចូលរួមសន្និសីទអន្តររដ្ឋាភិបាលជាន់ខ្ពស់ ដើម្បីអនុម័តលើកិច្ចព្រមព្រៀងជាសកលសម្រាប់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងទៀងទាត់ ។ សន្និសីទនេះ នឹងប្រព្រឹត្តទៅកម្រិតនយោបាយថ្នាក់ខ្ពស់ ដោយមានការចូលរួមពីប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល គ្រោងនឹងប្រារព្ធទៅពីថ្ងៃទី ១០ ដល់ ១១ ខែធ្នូ ឆ្នាំ ២០១៨ នៅទីក្រុងម៉ារ៉ាកេ្ហិច ប្រទេសម៉ារ៉ុក។

ដោយមានបញ្ជាក់ច្បាស់ក្នុងរបៀបវារៈឆ្នាំ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងការប្តេជ្ញាចិត្តនៅក្នុងសេចក្តីប្រកាសទីក្រុងញូយ៉ក កិច្ចព្រមព្រៀងជាសកលនេះនឹងក្លាយជាកិច្ចព្រមព្រៀងសកលដំបូងដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍ឲ្យបានល្អជាងមុននៅគ្រប់ទិដ្ឋភាពដើម្បីជាផលប្រយោជន៍សម្រាប់រដ្ឋនិងសហគមន៍ទាំងអស់ និងដោយផ្តោតសំខាន់លើសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ផងដែរ។

ការអនុម័តលើកិច្ចព្រមព្រៀងជាសកលនេះ គឺជាសមិទ្ធផលដ៏សំខាន់សម្រាប់ពហុភាគីនិយម។ កិច្ចព្រមព្រៀងនេះឆ្លុះបញ្ចាំងពីការយល់ដឹងរួមគ្នារបស់រដ្ឋាភិបាលថា ការធ្វើទេសន្តរប្រវេសន៍ឆ្លងដែនគឺជាបាតុភូតអន្តរជាតិ ហើយការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើតថភាពជាសកលនេះ ទាមទារនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍជាវិជ្ជមានសម្រាប់ទាំងអស់គ្នា។

ដូចដែលបានសម្រេចដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងសេចក្តីសម្រេចចិត្តលេខ ៧២/២៤៤ សន្និសីទនេះនឹងមានកិច្ចប្រជុំពេញអង្គ ហើយស្របគ្នានេះដែរ នឹងមានកិច្ចសន្ទនាកម្រិតខ្ពស់ចំនួនពីរ ដើម្បីស្វែងរកវិធានការជាក់ស្តែង ប្រកបដោយភាពច្នៃប្រឌិតដែលរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រព័ន្ធអង្គការសហប្រជាជាតិ និងភាគីពាក់ព័ន្ធដទៃទៀតអាចទទួលយកបានដើម្បីធ្វើឱ្យកិច្ចព្រមព្រៀងសកលនេះក្លាយជាការពិត។

ខ្ញុំសង្ឃឹមយ៉ាងខ្លាំងថា **សម្តេចតេជោនាយករដ្ឋមន្ត្រី** នឹងអញ្ជើញចូលរួមសន្និសីទជាប្រវត្តិសាស្ត្រនេះ ដោយទន្ទឹងរង់ចាំទទួលការបញ្ជាក់ពីការចូលរួមរបស់ **សម្តេច** តាមពេលវេលាសមស្រប។

សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ៕

ហត្ថលេខា
អាន់តូនីញ៉ូ ហ្គូថេរេស

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

THE SECRETARY-GENERAL

25 July 2018

Excellency,

I have the honour to invite you to attend the High-level Intergovernmental Conference to Adopt the Global Compact for Safe, Orderly and Regular Migration. The Conference, which will be held at the highest political level, including Heads of State and Government, will take place in Marrakesh, Morocco, on 10 and 11 December 2018.

Firmly rooted in the 2030 Agenda for Sustainable Development and the commitments made in the New York Declaration, the Global Compact will be the first global agreement designed to better manage international migration in all its dimensions for the benefit of all States and communities, and with the rights of all migrants at the fore.

The adoption of the Global Compact will be a significant achievement for multilateralism. The Compact reflects the shared understanding by Governments that cross-border migration is, by its very nature, an international phenomenon and that effective management of this global reality requires international cooperation to enhance its positive development effects for all.

As decided by the United Nations General Assembly in resolution 72/244, the Conference will consist of plenary meetings and, in parallel, two high-level dialogues that will explore concrete, innovative actions that governments, civil society organizations, the private sector, the United Nations system, and other stakeholders can take to make the Global Compact a reality.

His Excellency
Samdech Akka Moha Sena Padei Techo Hun Sen
Prime Minister of the Kingdom of Cambodia
Phnom Penh

International Organization for Migration (IOM)

The UN Migration Agency

អគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន

ចូល

លេខ 1627

ថ្ងៃទី 20 ខែ 11 ឆ្នាំ ២០18

ម៉ោង 16h15

H.E. Prak Sokhonn
Deputy Prime Minister
Ministry of Foreign Affairs and International Cooperation
Phnom Penh, Cambodia

20 November 2018

Ref: 18/279/IOM

Your Excellency,

The International Organization for Migration (IOM) presents its compliments to the Ministry of Foreign Affairs and International Cooperation.

Enclosed please find a letter of the UN Secretary-General sent to the Permanent Mission of the Royal Government of Cambodia to the United Nations Office regarding the invitation for the Government of Cambodia to attend High-level Intergovernmental Conference to Adopt the Global Compact for Safe, Orderly and Regular Migration. The Conference, which will be held at the highest political level, including Heads of State and Government, will take place in Marrakesh, Morocco, on 10 and 11 December 2018.

Please accept, Excellency, the assurances of my highest consideration.

Yours Sincerely,

INTERNATIONAL ORGANIZATION FOR MIGRATION IOM CAMBODIA

Leul A. MEKONNEN
Chief of Mission
IOM Mission in Cambodia

Tel: 012 367 489

រាជធានីភ្នំពេញ ថ្ងៃទី ខែវិច្ឆិកា ឆ្នាំ២០១៨

ឯកឧត្តម អានតូនីញ៉ូ ហ្គូថេរេស
អគ្គលេខាធិការអង្គការសហប្រជាជាតិ
<u>ទីក្រុងញូយ៉ក</u>

ឯកឧត្តម

ខ្ញុំបានទទួលលិខិតអញ្ជើញរបស់ **ឯកឧត្តម**ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៨ ដោយអញ្ជើញរូបខ្ញុំចូលរួមសន្និសីទអន្តររដ្ឋាភិបាលជាន់ខ្ពស់ ដើម្បីអនុម័តលើកិច្ចព្រមព្រៀងជាសកលសម្រាប់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងទៀងទាត់ ដែលគ្រោងនឹងប្រព្រឹត្តទៅពីថ្ងៃទី ១០ ដល់ ១១ ខែធ្នូ ឆ្នាំ ២០១៨ នៅទីក្រុង ម៉ារ៉ាហ្កិច ប្រទេសម៉ារ៉ុក។

ជាមួយការថ្លែងអំណរគុណយ៉ាងស្មោះចំពោះការអញ្ជើញរបស់**ឯកឧត្តម** ខ្ញុំពិតជាសោកស្តាយណាស់ ដោយសារកម្មវិធីមមាញឹកខ្លាំង ខ្ញុំពុំអាចចូលរួមកិច្ចប្រជុំដ៏មានសារៈសំខាន់ខាងលើនេះបានទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានចាត់តាំង **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ឱ្យចូលរួមកិច្ចប្រជុំនេះក្នុងនាមរូបខ្ញុំ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា កិច្ចប្រជុំដ៏មានសារៈសំខាន់និងជាប្រវត្តិសាស្ត្រនេះ នឹងនាំមកនូវលទ្ធផលប្រកបដោយផ្លែផ្កា សម្រាប់ការគ្រប់គ្រងទេសន្តរប្រវេសន៍អន្តរជាតិឱ្យកាន់តែប្រសើរឡើងនៅគ្រប់ទិដ្ឋភាព ដើម្បីជាផលប្រយោជន៍សម្រាប់គ្រប់រដ្ឋ និងសហគមន៍ទាំងអស់។

ខ្ញុំសូមជូនពរឱ្យកិច្ចប្រជុំនេះទទួលបានជោគជ័យធំធេង និងមានលទ្ធផលល្អ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ៕

ហ៊ុន សែន

Phnom Penh November 2018

**His Excellency Mr. Antonio Guterres**
Secretary General
United Nations

**New York**

Excellency,

I have received your letter dated 25 July 2018 inviting me to attend the High-level Intergovernmental Conference to Adopt the Global Compact for Safe, Orderly and Regular Migration to be held from 10 to 11 December 2018 in Marrakesh, Morocco.

While expressing my sincere thanks for your kind invitation, I very much regret to inform Your Excellency that due to my very tight schedule, I will not be able to attend the above-said important meeting. However, I have designated H.E Mrs. Chou Bun Eng, Secretary of State, Ministry of Interior, to attend this meeting on my behalf.

I am confident that this important and historic meeting will bring about fruitful results for better management of international migration in all its dimensions for the benefit of all States and communities.

May I wish the Meeting great success and productive outcomes.

Please accept, Excellency, the assurances of my highest consideration.

**HUN SEN**

ខុទ្ទកាល័យសម្តេចតេជោ
នាយករដ្ឋមន្ត្រី
ចូល ថ្ងៃទី 30 ខែ 11 ឆ្នាំ 2018
ម៉ោង: 16:30

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ ៤៧៦៤ កបទ-សអ/ច្បក២

ការប្រញាប់

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ**៖ការគោរពអញ្ជើញចូលរួមសន្និសីទអន្តររដ្ឋាភិបាលជាន់ខ្ពស់នៅប្រទេសម៉ារ៉ុក ។
**យោង** ៖លិខិតចុះថ្ងៃទី ២០ វិច្ឆិកា ២០១៨ របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅរាជធានីភ្នំពេញ ។

ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា តាមរយៈអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) នៅរាជធានីភ្នំពេញដែលក្រសួងទើបទទួលបាន លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានគោរពអញ្ជើញ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចូលរួមសន្និសីទអន្តររដ្ឋាភិបាលជាន់ខ្ពស់ (High-Level Intergovernmental Conference) ដើម្បីអនុម័តលើកិច្ចព្រមព្រៀងជាសកលសំរាប់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងទៀងទាត់ (Adopt the Global Compact for Safe, Orderly and Regular Migration) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ១០ ដល់ ១១ ធ្នូ ២០១៨ នៅទីក្រុងម៉ារ៉ាគិច ប្រទេសម៉ារ៉ុក ។

ដោយពេលវេលាគោរពអញ្ជើញ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មានរយៈពេលខ្លីពេក ហើយសន្និសីទខាងលើនេះ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក៏ធ្លាប់បានចូលរួមពិភាក្សារៀបចំឯកសារស្តីពី Global Compact for Safe, Orderly and Regular Migration កាលពីថ្ងៃទី ២២ ដល់២៣ កុម្ភៈ ២០១៨ នៅទីក្រុងញូវយ៉កផងដែរនោះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យល់ថា គួរចាត់ **លោកជំទាវ ជូ ប៊ុនអេង** ជាតំណាងកម្ពុជាចូលរួមសន្និសីទខាងលើ ។

សូមគោរពជូនភ្ជាប់លិខិតរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងលិខិតឆ្លើយតបរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** មេត្តាសម្រេច និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

ថ្ងៃ សុក្រ ៨រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨
**រដ្ឋមន្ត្រីស្តីទី**

**អ៊ុច បូររិទ្ធ**

3-12-18

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

...យដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ ៤៧៦៥ កបទ-សអ/ច្បក២

**ការប្រញាប់**

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ**៖ការគោរពអញ្ជើញចូលរួមសន្និសីទអន្តររដ្ឋាភិបាលជាន់ខ្ពស់នៅប្រទេសម៉ារ៉ុក ។
**យោង** ៖លិខិតចុះថ្ងៃទី ២០ វិច្ឆិកា ២០១៨ របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅរាជធានីភ្នំពេញ ។

ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា តាមរយៈអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) នៅរាជធានីភ្នំពេញដែលក្រសួងទើបទទួលបាន លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានគោរពអញ្ជើញ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចូលរួមសន្និសីទអន្តររដ្ឋាភិបាលជាន់ខ្ពស់ (High-Level Intergovernmental Conference) ដើម្បីអនុម័តលើកិច្ចព្រមព្រៀងជាសកលសំរាប់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងទៀងទាត់ (Adopt the Global Compact for Safe, Orderly and Regular Migration) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ១០ ដល់ ១១ ធ្នូ ២០១៨ នៅទីក្រុងម៉ារ៉ាគិច ប្រទេសម៉ារ៉ុក ។

ដោយពេលវេលាគោរពអញ្ជើញ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មានរយៈពេលខ្លីពេក ហើយសន្និសីទខាងលើនេះ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក៏ធ្លាប់បានចូលរួមពិភាក្សារៀបចំឯកសារស្តីពី Global Compact for Safe, Orderly and Regular Migration កាលពីថ្ងៃទី ២២ ដល់២៣ កុម្ភៈ ២០១៨ នៅទីក្រុងញូវយ៉កផងដែរនោះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យល់ថា គួរចាត់ **លោកជំទាវ ជូ ប៊ុនអេង** ជាតំណាងកម្ពុជាចូលរួមសន្និសីទខាងលើ ។

សូមគោរពជូនភ្ជាប់លិខិតរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងលិខិតឆ្លើយតបរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** មេត្តាសម្រេច និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។/.

ថ្ងៃ សុក្រ ៤កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីស្តីទី**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**អ៊ុច បូររិទ្ធ**

**ចម្លងជូន:**
-ទីស្តីការគណរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

Samdech Akka Moha Sena Padei Techo HUN SEN
Prime Minister of the Kingdom of Cambodia

Phnom Penh, 03 December 2018

His Excellency Mr. Antonio Guterres
Secretary General
United Nations
New York

Excellency,

I have received your letter dated 25 July 2018 inviting me to attend the High-level Intergovernmental Conference to Adopt the Global Compact for Safe, Orderly and Regular Migration to be held from 10 to 11 December 2018 in Marrakesh, Morocco.

While expressing my sincere thanks for your kind invitation, I very much regret to inform Your Excellency that due to my very tight schedule, I will not be able to attend the above-said important meeting. However, I have designated H.E Mrs. Chou Bun Eng, Secretary of State, Ministry of Interior, to attend this meeting on my behalf.

I am confident that this important and historic meeting will bring about fruitful results for better management of international migration in all its dimensions for the benefit of all States and communities.

May I wish the Meeting great success and productive outcomes.

Please accept, Excellency, the assurances of my highest consideration.

HUN SEN

គោលបំណងសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាពរៀបរយនិងទៀងទាត់

(១) ប្រមូលនិងប្រើប្រាស់ទិន្នន័យត្រឹមត្រូវនិងបែងចែកជាមូលដ្ឋានសម្រាប់គោលនយោបាយផ្អែកលើភស្តុតាង

(២) កាត់បន្ថយកត្តាអវិជ្ជមាននិងកត្តារចនាសម្ព័ន្ធដែល បង្ខំឲ្យ មនុស្សចាកចេញពីប្រទេសដើម

(៣) ផ្តល់ព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលានៅគ្រប់ដំណាក់កាលនៃការធ្វើចំណាកស្រុក

(៤) ធានាថាជនចំណាកស្រុកទាំងអស់មានភស្តុតាងអត្តសញ្ញាណនិងឯកសារគ្រប់គ្រាន់

(៥) លើកកម្ពស់ភាពអាចរកបាននិងភាពបត់បែននៃមាគ៌ាសម្រាប់ការធ្វើចំណាកស្រុកជាប្រចាំ

(៦) សម្របសម្រួលការជ្រើសរើសនិងលក្ខខណ្ឌការការពារប្រកបដោយភាពត្រឹមត្រូវនិងប្រកបដោយក្រមសីលធម៌ដែលធានាបាននូវការងារសមរម្យ

(៧) ដោះស្រាយនិងកាត់បន្ថយភាពងាយរងគ្រោះក្នុងការធ្វើចំណាកស្រុក

(៨) ជួយសង្គ្រោះជីវិតនិងបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិដែលបានសម្របសម្រួលលើជនចំណាកស្រុកដែលបាត់ខ្លួន

(៩) ពង្រឹងការឆ្លើយតបឆ្លងប្រទេសចំពោះការរត់ពន្ធជនចំណាកស្រុក

(១០) បង្ការប្រយុទ្ធប្រឆាំងនិងលុបបំបាត់ការជួញដូរមនុស្សក្នុងបរិបទអន្តោប្រវេសន៍អន្តរជាតិ

(១១) គ្រប់គ្រងព្រំដែនដោយសមាហរណកម្មសុវត្ថិភាពនិងសម្របសម្រួល

(១២) ពង្រឹងភាពជាក់លាក់និងការទស្សន៍ទាយក្នុងនីតិវិធីធ្វើចំណាកស្រុកសម្រាប់ការត្រួតពិនិត្យវាយតម្លៃនិងការបញ្ជូនសមស្រប

(១៣) ប្រើការឃុំឃាំងជនចំណាកស្រុកគ្រាន់តែជាវិធានការចុងក្រោយហើយធ្វើការឆ្ពោះទៅរកជម្រើសផ្សេង

(១៤) ពង្រឹងការការពារជំនួយនិងកិច្ចសហប្រតិបត្តិការកុងស៊ុលពេញមួយវដ្តនៃការធ្វើចំណាកស្រុក

(១៥) ផ្តល់លទ្ធភាពទទួលបានសេវាកម្មមូលដ្ឋានសម្រាប់ជនចំណាកស្រុក

(១៦) ផ្តល់សិទ្ធិអំណាចដល់ជនចំណាកស្រុកនិងសង្គមអោយមានការយល់ដឹងពេញលេញនិងការរួបរួមគ្នាក្នុងសង្គម

(១៧) លុបបំបាត់រាល់ទម្រង់នៃការរើសអើងនិងលើកកម្ពស់សុន្ទរកថាសាធារណៈផ្អែកលើភស្តុតាងដើម្បីបង្ហាញពីការយល់ឃើញនៃការធ្វើចំណាកស្រុក

(១៨) វិនិយោគលើការអភិវឌ្ឍជំនាញនិងសម្រួលដល់ការទទួលស្គាល់គ្នាទៅវិញទៅមកនូវជំនាញគុណវុឌ្ឍិនិងសមត្ថភាព

(១៩) បង្កើតលក្ខខណ្ឌសម្រាប់ជនចំណាកស្រុកនិងជនអន្តោប្រវេសន៍ដើម្បីចូលរួមចំណែកយ៉ាងពេញលេញដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសទាំងអស់

(២០) ជំរុញការផ្ញើរប្រាក់ផ្ញើរប្រាក់លឿននិងមានសុវត្ថិភាពនិងថោកជាងមុននិងជំរុញការដាក់បញ្ចូលហិរញ្ញវត្ថុរបស់ជនចំណាកស្រុក

**មតិស្វាគមន៍ និងរបាយការណ៍សង្ខេប**

**សម្រាប់សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពី**

តួនាទីរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក

ស្ដីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

សាលប្រជុំអគារ 'ទ' ទីស្តីការក្រសួងមហាផ្ទៃ

ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២០

ដោយ**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

សូមគោរពឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គស្នងការរង អគ្គនាយក អគ្គនាយករង

លោកស្រី **គ្រីស្ទីន** ប៉ាកូ ប្រធានប្រចាំប្រទេស អង្គការទេសន្តរប្រវេសន៍អន្តរជាតិ សមាជិក សមាជិកា នៃអង្គសិក្ខាសាលា ជាទីគោរពរាប់អាន

ក្នុងនាមអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏ឧត្តុង្គឧត្តម **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ លោកស្រី គ្រិស្ទីន ប៉ាកូ ប្រធានប្រចាំប្រទេសអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងជាតំណាងអង្គការសហប្រជាជាតិ នៅកម្ពុជា និងសមាជិក សមាជិកា នៃសិក្ខាសាលាទាំងអស់ ក្នុងសិក្ខាសាលាពិគ្រោះយោបល់ នាថ្ងៃនេះ ដែលជាការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា ចំពោះគោលបំណងនៃកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលជាភារកិច្ចដ៏មានសារសំខាន់ ក្នុងស្ថានភាពបច្ចុប្បន្ននេះ ។

មុននឹងឈានដល់ដំណាក់កាលនេះ ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្ត ក្នុងការចូលរួមរៀបចំ និងអនុម័តកតិកាសញ្ញានេះ ដោយបានឆ្លងកាត់ដំណាក់កាលជាបន្តបន្ទាប់ ដូចខាងក្រោម៖

**១. កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧** អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានទទួលការអនុញ្ញាតជាគោលការណ៍ ពីប្រមុខរាជរដ្ឋាភិបាល និងដោយមានកិច្ចសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ រៀបចំការពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ការចូលរួមក្នុងដំណើរការ រៀបចំកតិកាសញ្ញាពិភពលោក ដោយសិក្សាអំពីបញ្ហាប្រឈមនៅថ្នាក់ជាតិ ពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ដើម្បីឈានទៅ ការដាក់បញ្ចូលជាដំណោះស្រាយរួមគ្នា ដែលការពិគ្រោះយោបល់នេះ ត្រូវបានប្រារព្ធធ្វើឡើង **នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួម ១៧០នាក់** មកពីស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន និងទទួលបានការផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ពី **សម្តេច**

ក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា ។ ( [illegible] ) ។

២. **នៅថ្ងៃទី ៦-៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧** រាជរដ្ឋាភិបាល បានចាត់បញ្ជូន នាងខ្ញុំ ដែលជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឲ្យដឹកនាំគណៈប្រតិភូចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីត្រៀមរៀបចំកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ **នៅទីក្រុងបាងកក** រៀបចំដោយអង្គការ UNESCAP, IOM, ILO, UNDP, UNFPA, UNHCR, UN WOMEN និង UNODC ដើម្បីពិនិត្យវាយតម្លៃផលប៉ះពាល់នៃទេសន្តរប្រវេសន៍ លើវិស័យសង្គម និងសេដ្ឋកិច្ច ។

៣. **នៅថ្ងៃ ទី ៤-៦ ខែ ធ្នូ ឆ្នាំ ២០១៧** នាងខ្ញុំបានទទួលការអនុញ្ញាតជាថ្មី ទៅចូលរួមសន្និសីទអន្តរជាតិ ស្តីពី កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលសន្និសីទអន្តរជាតិ **នាទីក្រុង** Puerto Vallarta, **ប្រទេសម៉ិកស៊ិច** ដើម្បីពិភាក្សារៀបចំខ្លឹមសារ ដាក់បញ្ចូលក្នុងសេចក្តីព្រាងបឋម នៃកតិកាសញ្ញា ។

៤. **នៅថ្ងៃទី** ២០-២៣ ខែ កុម្ភៈ **ឆ្នាំ** ២០១៨ នាងខ្ញុំ បានទៅចូលរួមបន្តក្នុងកិច្ចប្រជុំបច្ចេកទេសពីតំណាងប្រទេសក្នុងពិភពលោក ដើម្បីពិភាក្សាបន្ថែមលើសេចក្តីព្រាងខ្លឹមសារកតិកាសញ្ញា រៀបចំដោយតំណាងពិសេស (Special Representatives of the Secretary General: SRSG) នៃអគ្គលេខាធិការដ្ឋាន សម្រាប់ទេសន្តរប្រវេសន៍អន្តរជាតិ និងរៀបចំនីតិវិធី **នាទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក** ។

៥. **និងជាចុងក្រោយ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានចាត់តាំងនាងខ្ញុំ ជាតំណាង ដើម្បីចូលរួមអនុម័ត កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ដែលប្រព្រឹត្តទៅ**នាទីក្រុង** ម៉ារ៉ាកិច **ប្រទេស** ម៉ារ៉ុក ថ្ងៃទី ១០-១១ ខែធ្នូ ឆ្នាំ ២០១៨ ។

**កតិកាសញ្ញានេះ មានគោលបំណងរួមចំនួន ២៣ ដូចមានចែកជូន ស្រាប់៖**

ដើម្បីបន្តការប្តេជ្ញាចិត្ត ក្នុងការធ្វើសកម្មភាពដើម្បីគាំទ្រកតិកាសញ្ញានេះ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស បានសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ រៀបចំកិច្ចប្រជុំបច្ចេកទេស ដែលមានសមាជិកមកពី ក្រសួងស្ថាប័នពាក់ព័ន្ធ កាលពីថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងគោលបំណងពិនិត្យពិភាក្សា និងជ្រើសរើសគោលបំណងជាអាទិភាព ក្នុងចំណោមគោលបំណងទាំង២៣ ដើម្បីត្រៀមដាក់ជូនសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី «តួនាទីរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់» នាថ្ងៃនេះ ។

ក្នុងកិច្ចប្រជុំ ក្រុមបច្ចេកទេស ពីអន្តរក្រសួង បានពិភាក្សាយ៉ាងល្អិតល្អន់ និង***បានជ្រើសរើសគោលបំណងអាទិភាពចំនួន ០៣ ដែលឆ្លើយតបទៅនឹងស្ថានភាពកម្ពុជា ព្រមទាំងជ្រើសរើសគោលបំណង បម្រុង ចំនួន ០៤ ទៀត ដែលមានសារៈសំខាន់ គួរពិនិត្យជ្រើសរើសជាអាទិភាពផងដែរ***។

**គោលបំណងអាទិភាព ចំនួន០៣ ដែលបានជ្រើសរើស ដោយក្រុមបច្ចេកទេស គឺ៖**

១. គោលបំណងទី៤៖ ធានាថាជនទេសន្តរប្រវេសន្តមានភ័ស្តុតាងអត្តសញ្ញាណ និងឯកសារគ្រប់គ្រាន់។

២. គោលបំណងទី១១៖ គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា។

៣. **គោលបំណងទី២៣៖** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

**គោលបំណងអាទិភាពបន្ថែម សម្រាប់ការពិភាក្សា ចំនួន០៤ គឺ៖**

១. **គោលបំណងទី១៖** ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមភេទជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើទិន្នន័យពិត។

២. **គោលបំណងទី៧៖** ដោះស្រាយ និងកាត់បន្ថយភាពងាយរងគ្រោះក្នុងដំណើរការទេសន្តរប្រវេសន៍។

៣. **គោលបំណងទី១២៖** ពង្រឹងឲ្យបាន និងត្រៀមទុកជាមុន នូវនីតិវិធីទេសន្តរប្រវេសន៍ សម្រាប់ការត្រួតពិនិត្យដោយសមស្រប ការប៉ាន់ប្រមាណបញ្ហា និងការបញ្ជូន។

៤. **គោលបំណងទី២០៖** ធ្វើឲ្យប្រសើរឡើងនូវការបញ្ជូន ឬការផ្ទេរប្រាក់ដែលឆាប់រហ័ស មានសុវត្ថិភាព តម្លៃទាប និងដាក់បញ្ចូលហិរញ្ញវត្ថុរបស់ជនទេសន្តរប្រវេសន៍។

នៅពេលដែលតំណាងក្រសួងពាក់ព័ន្ធ សម្រេចជ្រើសរើសជាអាទិភាពហើយ លទ្ធផលនៃកិច្ចពិភាក្សា នឹងត្រូវបានធ្វើសេចក្តីរាយការណ៍ជូន ឯកឧត្តម លោកជំទាវ ប្រធានស្ថាប័ន បានជ្រាប និងគាំទ្រ ហើយរាជរដ្ឋាភិបាលកម្ពុជា មានការកិច្ចដាក់បញ្ចូល គោលបំណងដែលពាក់ព័ន្ធទៅក្នុង ផែនការយុទ្ធសាស្ត្រ របស់ក្រសួងស្ថាប័ននីមួយៗ ដើម្បីរៀបចំ និងអនុវត្តសកម្មភាព ធ្វើឲ្យសម្រេច គោលបំណងអាទិភាពទាំងនោះ ។

អាស្រ័យហេតុនេះ **សូមសម្តេច ក្រឡាហោម** ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឯកឧត្តម លោកជំទាវ មេត្តាជ្រាប ដ៏ខ្ពង់ខ្ពស់ និងសូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ដៃគូអន្តរជាតិ ទទួលបាននូវពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមគោរពអរគុណ និងសូមអរគុណ**

**សុន្ទរកថាបើកកម្មវិធី**
**របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ**
**ស្តីពី**
**តួនាទីរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក**
**ស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់**

សាលប្រជុំអគារ 'S' ទីស្តីការក្រសួងមហាផ្ទៃ
ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២០

ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ
លោកស្រី តំណាងអង្គការសហប្រជាជាតិ
ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃអង្គសិក្ខាសាលា ជាទីរាប់អាន

ជាបឋម ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយ ដោយបានចូលរួមជាអធិបតីក្នុងសិក្ខាសាលានាថ្ងៃនេះ ដែលជាការបង្ហាញនូវការវិវត្តទៅមុខ នៃការអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងនូវអំណរគុណ និងកោតសរសើរចំពោះអង្គការសហប្រជាជាតិ នៅកម្ពុជា ជាពិសេស អង្គការ ទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលបានគាំទ្រ និងសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមរៀបចំ និងអនុវត្ត កតិកាសញ្ញាពិភពលោក ស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នេះ ។

ដូចឯកឧត្តមលោកជំទាវ លោក លោកស្រី បានជ្រាបរួចមកហើយថា កតិកាសញ្ញានេះ គឺផ្តើមចេញពីកង្វល់របស់ពិភពលោក ជុំវិញបញ្ហាទេសន្តរប្រវេសន៍ ដែលតែងទទួលរងនូវភាពប្រឈម តិច ឬច្រើន ពីការធ្វើទេសន្តរប្រវេសន៍ ជាអ្នកស្វែងរកការងារ ឬជាជនភៀសខ្លួនពីតំបន់មានគ្រោះអាសន្នជាដើម ។ តាមការស្រាវជ្រាវនៅទូទាំងពិភពលោក ត្រូវបានរកឃើញថា ជាទូទៅ ជនទេសន្តរប្រវេសន៍ភាគច្រើន ដែលគ្មានជំនាញ និងមិនស្របច្បាប់ ច្រើនស្ថិតក្នុងស្ថានភាពលំបាក និងរងគ្រោះច្រើនជាងអ្នកដែលមានការបញ្ជូនព្រមជាមួយឯកសារស្របច្បាប ។ ជនទេសន្តរប្រវេសន៍ដែលប្រថុយប្រថានចាកចេញ ដោយខ្វះកិច្ចការពារពីប្រព័ន្ធច្បាប់ តែងត្រូវបានជនឆ្លៀតឱកាស កេងប្រវ័ញ្ចយកផលចំណេញពីស្ថានភាពទ័លច្រករបស់អ្នកទាំងនោះ ដោយធ្វើការជួញដូរមនុស្ស រំលោភបំពាន កេងប្រវ័ញ្ចកម្លាំងពលកម្មធ្ងន់ធ្ងរ តាមបែបទាសភាព ធ្វើឲ្យធ្លាក់ខ្លួនជាពិការ វង្វេងស្មារតី បាត់បង់ភាពជាមនុស្ស ឬរហូតដល់បាត់បង់ជីវិត ដោយគ្មានសេសសល់អ្វី ត្រឡប់មកវិញ តាមការរំពឹងទុកនោះឡើយ ។

ក្នុងដំណាក់កាលបច្ចុប្បន្ន ការធ្វើទេសន្តរប្រវេសន៍រឹតតែប្រឈមខ្លាំង ដោយហេតុថា ការរាតត្បាតនៃជម្ងឺកូវីដ ១៩ នៅមិនទាន់ស្ងប់ស្ងាត់នៅឡើយ មិនតែប៉ុណ្ណោះ ប្រទេសមួយចំនួន បាន និងកំពុងតែកើនឡើង

នូវចំនួនអ្នកឆ្លងថ្មី យ៉ាងច្រើនលើសលប់ រៀងរាល់ថ្ងៃ ។ ស្ថានភាពនេះ បានធ្វើឲ្យប្រទេស ដែលទទួលពលករ ក៏ប្រឈមខ្លាំងទៅនឹងភាពប្រែប្រួលជាអវិជ្ជមាននៃចរន្តសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចក្នុងស្រុក ដែលជំរុញឲ្យដំណើរការនៃរោងចក្រសហគ្រាស និងវិស័យសេវាកម្មនានារាំងស្ទះ និងត្រូវផ្អាកដំណើរការជាបន្តបន្ទាប់ ។ ចំណែកឯវិធានការបិទព្រំដែន និងបិទការនាំចូលពលករបរទេស ក៏នៅបន្ត ដែលជាហេតុធ្វើឲ្យពលករ ត្រូវធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់ថា តើគួរបន្តស្នាក់នៅក្នុងប្រទេសគោលដៅដោយមិនមានការងារ ប្រាក់ចំណូល ឬក៏ត្រូវត្រឡប់មកភូមិស្រុកវិញ ដើម្បីជួបជុំគ្រួសារ? ។

គិតចាប់ពីថ្ងៃទី២១ ខែមិនា រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ មានពលករកម្ពុជាដែលវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ ក្នុងអំឡុងកូវីដ ១៩ មានប្រមាណ ១០ម៉ឺន៣ពាន់នាក់ និងស្ត្រី ប្រមាណ ៤៥ ភាគរយ ។ យើងបាន និងកំពុងទទួលសង្គ្រោះពលករ ដែលវិលត្រឡប់មកវិញ ដោយគេចវេសពីស្ថានភាពលំបាក ក្នុងប្រទេសគោលដៅ និងព្យាយាមឆ្លងដែនដោយខុសច្បាប់ និងតាមច្រកមិនផ្លូវការ ក្នុងអំឡុងពេលដែលប្រទេសគោលដៅបាន និងកំពុងរឹតបន្តឹង និងបិទប្រទេស ដើម្បីកាត់បន្ថយការឆ្លងទៅមក នូវជម្ងឺកូវីដ ១៩ ។ ស្ថានភាពបែបនេះ នឹងមិនអាចបញ្ចប់ដោយងាយៗនោះទេ ហើយក៏អាចអូសបន្លាយបន្តទៀតក្នុងរយៈពេលវែង ហេតុនេះ កិច្ចការពារពលករ ទាំងនៅក្នុងប្រទេសដើម ទាំងនៅក្នុងប្រទេសគោលដៅ គឺជាភារកិច្ចចាំបាច់ ដែលគប្បីត្រូវយកចិត្តទុកដាក់ ។

ដោយឡែក រាជរដ្ឋាភិបាលកម្ពុជា ក៏បានយកចិត្តទុកដាក់ចំពោះបញ្ហានេះ ព្រោះ ប្រជាជនកម្ពុជា បាន និងកំពុងតែ ទទួលរងនូវស្ថានភាពទាំងអស់នេះ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាតំណាងឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយមានកិច្ចសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ខ្ញុំ បានដឹកនាំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិជាលើកដំបូង នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ដោយមាន តំណាង មកពីក្រសួងពាក់ព័ន្ធ ស្ថាប័នរដ្ឋទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល និងស្ថាប័នឯកជន ប្រមាណ ១៧០នាក់ ។ កាលនោះ យើងបានឯកភាពគ្នាជ្រើសយកបញ្ហាជាអាទិភាពដែលពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ ក៏ដូចជាសំណូមពរដោះស្រាយជាច្រើនចំណុច ដើម្បីយកទៅដាក់បញ្ចូលជាមួយបណ្តាប្រទេសផ្សេងទៀត នៅក្នុង តំបន់ ។ ជាបន្តបន្ទាប់ រាជរដ្ឋាភិបាលកម្ពុជា បានចាត់តាំងលោកជំទាវ ជូ ប៊ុនអេង ជាតំណាងចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់ រៀបចំដោយ UNESCAP ដើម្បីពិភាក្សាលើបញ្ហាទេសន្តរប្រវេសន៍ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងសង្គម នៅទីស្នាក់ការអង្គការសហប្រជាជាតិទីក្រុងបាងកក - កិច្ចប្រជុំតំណាងប្រទេស ពីតំបន់នានា នៅទីក្រុង Perto-Vallarta ប្រទេសម៉ិកស៊ិច រៀបចំ សេចក្តីព្រាងបឋម និងទៅចូលរួមពិភាក្សាសេចក្តីព្រាងបឋមនេះ នៅអង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក និងចុងក្រោយ ចូលរួមអនុម័ត សេចក្តីព្រាងចុងក្រោយ នៃកាតិកាសញ្ញា នៅទីក្រុង ម៉ារ៉ាកិច ប្រទេសម៉ារ៉ុក នៅថ្ងៃទី១២ ខែធ្នូ ដូចលោកជំទាវជូ ប៊ុនអេង បានបញ្ជាក់ក្នុងរបាយការណ៍ស្រាប់ ។

ក្រោយពីកតិកាសញ្ញានេះចូលជាធរមាន អង្គការសហប្រជាជាតិ បានដាក់ចេញនូវគោលបំណងចំនួន ២៣ ដើម្បីដាក់ជូនប្រទេសនានា ដែលជាសមាជិក ធ្វើការជ្រើសរើស ផ្អែកទៅតាមស្ថានភាព និងអាទិភាពតាមប្រទេសនីមួយៗ ។ ដូចលោកស្រី គ្រិស្ទីន ប៉ាកូ បានបញ្ជាក់រួចហើយ ថា គោលដៅទាំង២៣ ដែលបានកំណត់នេះ គឺជាការបំពេញបន្ថែមលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបវារៈសម្រាប់ឆ្នាំ២០៣០ ។

ដើម្បីបន្តជម្រុញការអនុវត្តកតិកាសញ្ញាពិភពលោកនេះ រដ្ឋជាសមាជិកនីមួយ ត្រូវធ្វើការជ្រើសរើសគោលបំណងជាអាទិភាពមួយចំនួន ដើម្បីធ្វើឲ្យបានសម្រេច ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សជាសេនាធិការ បានសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធទាំងឡាយដើម្បីធ្វើការជ្រើសរើស ដោយឯកភាពគ្នា និងដើម្បីជាការទទួលខុសត្រូវរួមគ្នា ក្នុងការអនុវត្ត ដើម្បីលើកកម្ពស់សុវត្ថិភាព និងភាពរៀបរយ ស្របច្បាប់ របស់ពលករទេសន្តរប្រវេសន៍ ។ មុននឹងចូលដល់ការសម្រេចក្នុងការជ្រើសរើសនេះ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ បានរៀបចំកិច្ចប្រជុំបច្ចេកទេសមួយ ដើម្បីជជែកពិភាក្សា និងពិនិត្យរកជម្រើសក្នុងចំណោមគោលបំណងទាំង ២៣ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ នៅរាជធានីភ្នំពេញ ដោយធ្វើការជ្រើសរើសបឋម នូវគោលបំណងចំនួនបី និងមានគោលបំណងត្រៀមចំនួនបួន សម្រាប់ការពិភាក្សាឡើងវិញ ក្នុងថ្ងៃនេះ ។ បន្ទាប់ពីការសម្រេចក្នុងកិច្ចប្រជុំនេះ ព្រះរាជាណាចក្រកម្ពុជា នឹងសម្រេចដាក់បញ្ចូលគោលបំណងដែលជ្រើសរើសបាន ទៅក្នុងផែនការសកម្មភាពឆ្នាំបន្តបន្ទាប់ ដើម្បីធានាថា ការធ្វើទេសន្តរប្រវេសន៍របស់ប្រជាជនកម្ពុជា ទៅប្រទេសគោលដៅទាំងឡាយ ក៏ដូចជា ជនទេសន្តរប្រវេសន៍ដែលមកពីប្រទេសក្រៅចូលក្នុងព្រះរាជាណាចក្រកម្ពុជា នឹងប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។

នៅក្នុងកិច្ចប្រជុំត្រៀមនេះ តំណាងពីអន្តរក្រសួង បានផ្តោតការយកចិត្តទុកដាក់លើវិស័យ ០៤ ដែលពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ គឺ៖

១. **ការការពារជនទេសន្តរប្រវេសន្ត** — ទាំងជនទេសន្តរប្រវេសន្តប្រក្រតី និងជនទេសន្តរប្រវេសន្តមិនប្រក្រតី ទាំងអ្នកដែលមានគម្រោងចាកចេញទៅធ្វើការក្រៅប្រទេស ទាំងអ្នកដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស ទាំងអ្នកវិលត្រឡប់មកវិញ ។

២. **ការគ្រប់គ្រងទិន្នន័យ** — ការរៀបចំប្រព័ន្ធទិន្នន័យសម្រាប់កត់ត្រា និងគ្រប់គ្រងឲ្យបានជាក់លាក់ នូវទិន្នន័យ ជនទេសន្តរប្រវេសន្តទាំងប្រក្រតី និងមិនប្រក្រតី ដើម្បីងាយស្រួលក្នុងការដាក់វិធានការឆ្លើយតបទៅនឹងស្ថានភាពនានា ដែលជាភាពប្រឈមរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ ។

៣. **ការគាំទ្រដំណើរការ នៃការវិលត្រឡប់ និងការធ្វើសមាហរណកម្មជនទេសន្តរប្រវេសន៍** — ត្រូវការរៀបចំគោលនយោបាយ វិធានការ និងនីតិវិធីជាក់លាក់ ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលនៃប្រទេសពាក់ព័ន្ធ ដើម្បីទទួលបានទិន្នន័យ លក្ខខណ្ឌនៃការបញ្ជូន វិធីបញ្ជូន ជាពិសេស ការកំណត់វិធានការការពារស្ត្រី និងកុមារ ដែលសង្ស័យថារងគ្រោះ ជាពិសេសដោយអំពើជួញដូរមនុស្ស

៤. **ការកំណត់ និងការផ្តល់អត្តសញ្ញាណដោយស្របច្បាប់** — ជាពិសេសសម្រាប់កូនរបស់ជនទេសន្តរប្រវេសន្តកម្ពុជា ដែលបានកើតនៅក្រៅប្រទេសកម្ពុជា។

ដូច្នេះ ខ្ញុំស្នើឲ្យអង្គសិក្ខាសាលា យកចិត្តទុកដាក់ក្នុងការត្រិះរិះពិចារណាបន្ថែមលើលទ្ធផលនៃការជ្រើសរើសបឋម ដោយក្រុមការងារបច្ចេកទេសអន្តរក្រសួង និងផ្អែកលើស្ថានភាព និងលទ្ធភាពជាក់ស្តែងរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីអាចធ្វើឲ្យសម្រេចបានតាមការរំពឹងទុក ។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរដល់អង្គសិក្ខាសាលា សូមទទួលបាននូវលទ្ធផលជាផ្លែផ្កា និងសូមប្រកបដោយពុទ្ធពរទាំង ប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ

សន្ទរកថារបស់លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្ម
អង្គការអន្តរជាតិទេសន្តរប្រវេសន៍ ប្រចាំនៅកម្ពុជា
(តំណាងឱ្យលោកស្រី ផូលីន ថាម៉េស៊ីស ប្រធានសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា)
ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ឯកឧត្តម លោកជំទាវ និងរដ្ឋមន្ត្រី តំណាងកិត្តិយសមកពីក្រសួងផ្សេងៗ៕
អស់លោក លោកស្រី អ្នកនាងកញ្ញា
អរុណសួស្តី

នេះជាកិត្តិយស និងឯកសិទ្ធិដ៏ធំធេងសម្រាប់ខ្ញុំ ដែលបានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ ក្នុងនាមនាងខ្ញុំតំណាងឱ្យលោកស្រី ផូលីន ថាម៉េស៊ីស ប្រធានសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចក្រឡាហោម ដែលបានយកចិត្តទុកដាក់ និងប្តេជ្ញាចំពោះការសម្រេចបាន និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

ការអនុម័តរបស់កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅខែធ្នូ ឆ្នាំ ២០១៧ គឺជាសមិទ្ធិផលដ៏ល្អមួយ។ នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៃអង្គការសហប្រជាជាតិ ដែលមានរដ្ឋសមាជិកភាគច្រើនសាមគ្គី និងរួបរួមគ្នាក្នុងការប្តេជ្ញាចិត្ត លើកកម្ពស់កិច្ចសហប្រតិបត្តិការលើបញ្ហាទេសន្តរប្រវេសន៍អន្តរជាតិ ដើម្បីទទួលបានផលប្រយោជន៍ជាអតិបរមាក្នុងពេលដោះស្រាយបញ្ហា និងបញ្ហាប្រឈមរបស់ខ្លួន។

សព្វថ្ងៃនេះ យើងឃើញថា យើងស្ថិតនៅក្នុងជំហរមួយដែលមិនអាចយល់បានកាលពី ២០ ឆ្នាំមុន។ អ្វីដែលយើងមាននៅចំពោះមុខយើងគឺជាផែនការដែលមិនធ្លាប់មានពីមុនមក និងមិនមានលក្ខណៈស្របច្បាប់ដែលបង្ហាញនូវចក្ខុវិស័យ ៣៦០ ដឺក្រេនៃបញ្ហាទេសន្តរប្រវេសន៍អន្តរជាតិ និងក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ។

ក្រោមការដឹកនាំដោយគោលការណ៍ណែនាំ និងគោលបំណងចំនួន ២៣ រដ្ឋសមាជិកនឹងជួយសង្គ្រោះជីវិត ធ្វើឱ្យប្រសើរឡើងនូវលក្ខខ័ណ្ឌរស់នៅ សមាហរណកម្មសហគមន៍ និងបង្កើនភាពរុងរឿងក្នុងលក្ខណៈមួយដែលបំពេញបន្ថែមរបៀបវារៈឆ្នាំ ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ឯកសារស្តីពីកតិកាសញ្ញាពិភពលោក បានជំរុញរដ្ឋជាសមាជិកទាំងអស់បង្កើតផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយសម្រាប់អនុវត្ត ។ កតិកាសញ្ញានេះជាឱកាសមួយសម្រាប់អនុវត្តការងារបន្តទាក់ទងនឹងបញ្ហាសំខាន់ៗនៃទេសន្តរប្រវេសន៍ ដែលមាននៅក្នុងរបៀបវារៈឆ្នាំ២០៣០ នៃការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងធានាថា ជនទេសន្តរប្រវេសន្តនឹងមិនត្រូវបានបោះបង់ចោលទេ។ កតិកាសញ្ញាផ្តល់ឱ្យជាពិសេស នូវឱកាសពិតដល់រដ្ឋសមាជិក ដើម្បីបញ្ជាក់ច្បាស់សារជាថ្មីនូវការអនុវត្តការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងកំណត់ក្រិតក្រមពាក់ព័ន្ធក្នុងគោលនយោបាយទេសន្តរប្រវេសន៍អន្តរជាតិ ដោយដោះស្រាយកង្វះចន្លោះ មួយចំនួននៅក្នុងកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។

ទេសន្តរប្រវេសន៍មានសក្តានុពលក្នុងការជះឥទ្ធិពលយ៉ាងជ្រាលជ្រៅ ដល់ជីវិតរបស់មនុស្សឱ្យកាន់តែប្រសើរឡើង។ វាផ្តល់ជូនបុគ្គលម្នាក់ៗនូវការសាកល្បងនូវឱកាសថ្មីៗក្នុងការងារការអប់រំសុខភាពនិងជីវិតគ្រួសារ និង អាចលើកកម្ពស់សុខុមាលភាព និងកម្រិតជីវភាពទូទៅរបស់ទាំងអ្នកដែលផ្លាស់ទីលំនៅ ព្រមទាំងការចាកចេញពីគ្រួសាររបស់ពួកគេ ។ សង្គមទាំងមូលក៏ទទួលបាននូវអត្ថប្រយោជន៍ពីអ្វីដែលជនទេសន្តរប្រវេសន្តត្រូវផ្តល់ជូន។

ជនទេសន្តរប្រវេសន៍ បានជួយបំពេញតំរូវការកំលាំងពលកម្មនិងជំនាញ ដែលត្រូវការជាច្រើន ។ ពួកគេបានរួមចំណែកដល់មូលដ្ឋានពន្ធ បង្កើតអាជីវកម្មដើម្បីផ្គត់ផ្គង់ទំនិញ សេវាកម្ម និងការងារដើម្បីទទួលប្រជាជន ហើយពួកគេក៏បានបង្កើតសង្គមមួយប្រកបដោយភាពច្នៃប្រឌិត និងរស់រវើកផងដែរ។

ទោះជាមានការចូលរួមចំណែកដ៏ច្រើនលើសលុបពីជនចល័ត និងជនទេសន្តរប្រវេសន្ត ដែលនាំមកនូវការអភិវឌ្ឍប្រកបដោយចីរភាពនៅគ្រប់តំបន់ទាំងអស់នៃពិភពលោកក៏ដោយ នៅមានចំនួនជនទេសន្តរប្រវេសន្តមួយចំនួនធំ ជាពិសេសអ្នកដែលស្ថិតក្នុងស្ថានភាពមិនប្រក្រតី គឺមិនត្រូវបានគេយកចិត្តទុកដាក់ ។ ខណៈពេលដែលជនទេសន្តរប្រវេសន្តខ្លះអាចទទួលបាននូវការអប់រំសុខភាព និងលទ្ធផលការងារ កាន់តែប្រសើរតាមរយៈការធ្វើទេសន្តរប្រវេសន៍ ជនទេសន្តរប្រវេសន្តមួយចំនួនទៀតប្រឈមនឹងបញ្ហាធ្ងន់ធ្ងរ ដូចជារងការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរក្នុងដំណើរការទេសន្តរប្រវេសន៍។

ជនទេសន្តរប្រវេសន្តតែងតែប្រឈមនឹងភាពងាយរងគ្រោះកាន់តែច្រើនឡើងៗ នៅក្នុងដំណើរការទេសន្តរប្រវេសន៍ និងនៅក្នុងប្រទេសគោលដៅរបស់ពួកគេ ដូចជាកង្វះលទ្ធភាពក្នុងការទទួលបាននូវសេវាកម្មមូលដ្ឋាន ការជួញដូរមនុស្ស អំពើហឹង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាននិង កម្លាំងពលកម្មនៅពេលពួកគេចាកចេញពីរដ្ឋជានីរបស់ពួកគេ ព្រមទាំងយន្តការការពារសម្រាប់ពួកគេនៅពេលពួកគេចាកចេញពីលំនៅដ្ឋាន។ នេះក៏ជាករណីសម្រាប់អ្នកដែលស្ថិតក្នុងស្ថានភាពវិបត្តិដែលបណ្តាលមកពីសង្គ្រាម ឬគ្រោះធម្មជាតិដែលងាយប្រឈមមុខនឹងការរងគ្រោះ និងការព្រួយបារម្ភពិសេសមួយទៀតគឺ ការរាតត្បាតនៃជំងឺ នាពេលបច្ចុប្បន្ននេះដែលយើងទាំងអស់គ្នាកំពុងតែប្រឈមនៅឆ្នាំនេះ។ ជនទេសន្តរប្រវេសន្តអន្តរជាតិខ្លះក្នុង ចំណោម ២៧២ លាននាក់នៅទូទាំងពិភពលោក ត្រូវបានប្រទះឃើញថាងាយរងគ្រោះជាងអ្នកដទៃទៀត ដោយសារកត្តាផ្ទាល់ខ្លួន សង្គមស្ថានភាពជាក់ស្តែង និងរចនាសម្ព័ន្ធ។ក្នុងស្ថានភាពវិបត្តិមួយនេះបានធ្វើឱ្យ ភាពងាយរងគ្រោះរបស់ពួកគេកាន់តែធ្ងន់ធ្ងរ ដូចគ្នានឹងការការពារជំងឺរាតត្បាតកូវីដ ១៩ ដែរ។ នៅប្រទេស កម្ពុជា ផលប៉ះពាល់នៃជំងឺកូវីដ ១៩ បានធ្វើឱ្យពលករទេសន្តរប្រវេសន្តជាង ១០០.០០០ នាក់ បានវិលត្រឡប់មក ប្រទេសវិញនៅខែមីនា ឆ្នាំ ២០២០ ។

ជាមួយនឹងវិធានការណ៍ដែលបានណែនាំដោយរដ្ឋាភិបាលជាច្រើនដើម្បីធ្វើឱ្យមានភាពថយចុះនៃការចម្លង ជំងឺកូវីដ ១៩ កំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការបំផ្លាស់ទី និងទេសន្តរប្រវេសន៍។ ការរឹតត្បិតការធ្វើដំណើរត្រូវបានអនុម័តដើម្បីគ្រប់គ្រងវីរុស រួមទាំងការហាមឃាត់មិនឱ្យចូលរស់នៅរបស់ប្រជាជនមកពីប្រទេសផ្សេងទៀត ហេតុនេះហើយប្រទេសខ្លះបានបិទព្រំដែនរបស់ពួកគេទាំងស្រុង។ ទេសន្តរប្រវេសន៍ការងារត្រូវបានផ្អាក ជាបណ្តោះអាសន្ននៅក្នុងប្រទេសមួយចំនួន ខណៈពេលដែលនៅក្នុងប្រទេសខ្លះដំណើរការទេសន្តរប្រវេសន៍ និងជំនួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោនកំពុងថយចុះ។

វាជាការសំខាន់ណាស់ដែលដំណើរការរបស់កតិកាសញ្ញា ត្រូវបានដឹកនាំដោយការប្តេជ្ញាចិត្ត ព្រមទាំងបង្កើតភាពរួមគ្នាជាមួយក្របខណ្ឌផ្សេងៗដូចជារបៀបវារៈឆ្នាំ២០៣០ ក្របខណ្ឌសកម្មភាពទីក្រុងសិនដាយ

របៀបវារៈសកម្មភាពទីក្រុងអាឌីស អាបាបា កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីបម្រែបម្រួលអាកាសធាតុ និងរបៀបវារៈទីក្រុងថ្មីៗព្រមទាំងការប្តេជ្ញា និងយន្តការមានស្រាប់ផ្សេងៗទៀត ដែលទាក់ទងនឹងបញ្ហាទេសន្តរ ប្រវេសន៍។

សម្តេចក្រឡាហោមជាទីគោរព ឯកឧត្តម និងលោកជំទាវ

គោលបំណងចំនួន ៧ ដែលត្រូវបានជ្រើសរើសជាមុនកាលពីថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០២០ ដោយតំណាងផ្សេងៗគ្នា នៃក្រសួងនិងស្ថាប័នសំខាន់ៗ ពីក្នុងចំនោមគោលបំណងទាំង ២៣ របស់កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ ដែលនឹងត្រូវបង្ហាញនៅថ្ងៃនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះ របស់យើងក្នុងការជ្រើសរើសវិធីដោះស្រាយយ៉ាងហោចណាស់ ២ ទៅ ៣ យ៉ាងដែលអាចអនុវត្តចំពោះបញ្ហាប្រឈម នៃទេសន្តរប្រវេសន៍នាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ហើយនឹងធ្វើជាមូលដ្ឋានសម្រាប់ការអនុវត្តរបស់កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ និងអាចរាយការណ៍អំពីសមិទ្ធិផលរបស់ រដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០២២ ។

តាមរយៈកិច្ចពិភាក្សាអន្តរជាតិស្តីពីទេសន្តរប្រវេសន៍ ចំនុចសំខាន់ៗចំនួនបួន (០៤) ត្រូវបានកំណត់ថាជាអាទិភាពនៃទេសន្តរប្រវេសន៍នៅក្នុងពេលខាងមុខនេះៈ

១. តួនាទីដែលជនទេសន្តរប្រវេសន្ត និងការធ្វើទេសន្តរប្រវេសន៍អាចដើរតួក្នុងការខិតខំប្រឹងប្រែងយ៉ាងលឿនដើម្បីឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបនៃការធ្វើសកម្មភាពលើបញ្ហាប្រឈមនឹងឱកាសផ្សេងៗគ្នានៃការធ្វើទេសន្តរប្រវេសន៍ អាចនាំមកនូវការចូលរួមចំណែកវិជ្ជមានរបស់ជនទេសន្តរប្រវេសន្តឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

២. ជាបញ្ហាឆ្លងកាត់ដ៏សំខាន់មួយនៅក្នុងរបៀបវារៈឆ្នាំ ២០៣០ ដែលភាគច្រើនទាក់ទងនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បញ្ហាទេសន្តរប្រវេសន៍អាចជាកត្តាជំរុញនៃការអភិវឌ្ឍប្រកបដោយចីរភាព ដូច្នេះ បញ្ហាទេសន្តរប្រវេសន៍គួរតែត្រូវបានដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍជាតិ។

៣. ទិន្នន័យនៃទេសន្តរប្រវេសន៍នៅតែមានចំនួនតិចតួចណាស់ នៅពេលខ្លះមិនអាចទុកចិត្តបាននោះទេ។ ហេតុនេះហើយយើងត្រូវធ្វើបន្ថែមទៀតដើម្បីធានាថា ទិន្នន័យទេសន្តរប្រវេសន៍ត្រូវបានប្រមូលជាលក្ខណៈប្រព័ន្ធ វិភាគនិងប្រើប្រាស់ដើម្បីជូនដំណឹងដល់គោលនយោបាយ ។ ការធ្វើបែបនេះអាចធ្វើទៅបានតាមរយៈ ការពិពណ៌នាលំអិត នៃផែនការជាតិស្តីពីទិន្នន័យ អំពីទេសន្តរប្រវេសន៍ឬដោយបញ្ចូលសំណួរដែលទាក់ទងនឹងទេសន្តរប្រវេសន៍ទៅក្នុងការធ្វើជំរឿន។ សំណួរនេះនឹងក្លាយជាចំណុចកណ្តាលនៅពេលពិភាក្សាអំពី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី១៧.១៨ ស្តីពីការបែងចែកទិន្នន័យជាពិសេស។

៤. អនុវត្តសកម្មភាពជាក់លាក់ដែលមានភាពស៊ីសង្វាក់គ្នាៈ អនុឡោមតាមស្ថានភាពដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក រដ្ឋាភិបាលត្រូវការយុទ្ធសាស្ត្រដែលផ្តោតទៅលើផ្នែកទាំងមូលនៃរដ្ឋាភិបាល ដើម្បីអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងវិធីសាស្ត្រផ្សេងៗដែលកតិកាសញ្ញាអាចជួយសម្រេចបាននូវទិសដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះ យើងក៏ត្រូវការនូវ ការសម្របសម្រួលរវាងក្រសួងចម្រុះ ព្រមទាំងជាមួយអ្នកពាក់ព័ន្ធ ដូចជាអជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់សង្គមស៊ីវិល ផ្នែកឯកជន អង្គការអន្តរជាតិ និងអ្នកទាំងឡាយណាដែលមានការជាប់ពាក់ព័ន្ធទាំងអស់។

ដើម្បីឱ្យដំណើរការធ្វោះទេសន្តរប្រវេសន៍ និងជនទេសន្តរប្រវេសន្តដើរតួនាទីជាភ្នាក់ងារសកម្មក្នុងការលុបបំបាត់ភាពក្រីក្រ និង លើកកម្ពស់វិបុលភាពវាចាំបាច់ត្រូវមានរចនាសម្ព័ន្ធល្អដើម្បីគ្រប់គ្រងទេសន្តរប្រវេសន៍ដើម្បីទទួលបាន ផលប្រយោជន៍ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។ ជាការពិតណាស់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កំណត់គោលនយោបាយទេសន្តរប្រវេសន៍ ដែលត្រូវបានគ្រប់គ្រងយ៉ាងល្អ ជាកត្តាគន្លឹះក្នុងការកាត់បន្ថយវិសមភាពដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍។

អង្គការសហប្រជាជាតិ និងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ នឹងជួយគាំទ្រប្រទេសកម្ពុជាក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ ជាមួយគ្នានេះដែរ យុទ្ធសាស្ត្រផ្តោតលើសង្គមទាំងមូលនឹងក្លាយជាគន្លឹះក្នុងការធានាថា ការអនុវត្តកតិកាសញ្ញាពិភពលោកនឹងមានភាពពេញលេញ ។ ផែនការថ្នាក់ជាតិនេះនឹងទទួលបានអត្ថប្រយោជន៍ពីការពិគ្រោះយោបល់ និងការរួមបញ្ចូលទស្សនៈរបស់ ជនទេសន្តរប្រវេសន្ត សហគមន៍មូលដ្ឋាន សង្គមស៊ីវិល វិស័យឯកជន ការសិក្សា អ្នកតំណាងរាស្ត្រ សហជីពស្ថាប័ន សិទ្ធិមនុស្សថ្នាក់ជាតិនិងអ្នកដទៃទៀត ។ ឧទាហរណ៍ មណ្ឌលបោះឆ្នោតទាំងនេះអាចបន្ថែមតម្លៃសំខាន់ៗក្នុងការកំណត់អាទិភាពក៏ដូចជាការតាមដាន និងពិនិត្យឡើងវិញនៃការអនុវត្តនៅថ្នាក់ជាតិ ។ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា ក្នុងនាមជាអ្នកសម្របសម្រួលរបស់បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍ ព្រមទាំងស្ថាប័នអង្គការសហប្រជាជាតិទាំងអស់ ត្រៀមខ្លួនជាស្រេចដើម្បីជួយនាំមកនូវជំនាញពេញលេញ នៃទីភ្នាក់ងារចូលរួមរបស់អង្គការសហប្រជាជាតិ ដើម្បីធានាបាននូវការគាំទ្រយ៉ាងពេញទំហឹងពីប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ដែលមានប្រសិទ្ធិភាពដល់រដ្ឋជាសមាជិកក្នុងការអនុវត្ត ការធ្វើបន្ត និងពិនិត្យឡើងវិញនូវកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍។ ជាចុងបញ្ចប់ ខ្ញុំមានជំនឿថា ការពិភាក្សាបើកចំហរ និងអន្តរកម្មនៅថ្ងៃនេះ ព្រមទាំងគំនិតផ្តួចផ្តើមជាក់ស្តែងដែលនឹងជួយធ្វើឱ្យមានការជំរុញសន្ទុះដែលយើងត្រូវការ ដើម្បីសម្រេចបាននូវចក្ខុវិស័យដែលបានកំណត់នៅ ក្នុងកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍។

សូមអរគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កម្មវិធី

## សិក្ខាសាលាថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំ ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)

ថ្ងៃព្រហស្បតិ៍ ១០កើត ខែស្រាពណ៍ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០
ទីស្តីការក្រសួងមហាផ្ទៃអគារ ៥ (ធំ)

| ពេលវេលា | បរិយាយសកម្មភាព | កំណត់សម្គាល់ |
|---|---|---|
| ០៧:៣០-០៨:០០ | សមាជិក សមាជិកានៃអង្គសិក្ខាសាលាអញ្ជើញដល់<br>- ការចុះឈ្មោះ<br>- វាស់កម្តៅ (Screening) | |
| ០៨:០០-០៨:៤៥ | សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ អញ្ជើញដល់ | គោរពទទួលស្វាគមន៍ សម្តេចក្រឡាហោម |
| ០៨:៤៥-០៩:៣០ | ចាប់ផ្តើមកម្មវិធី៖<br>- គោរពទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា<br>- មតិស្វាគមន៍ដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)<br>- សន្ទរកថាដោយ លោកស្រី Kristin Parco ប្រធានបេសកកម្ម នៃអង្គការ IOM និងជាតំណាងអង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា<br>- សន្ទរកថាបើកកម្មវិធីដោយ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ<br>- ថតរូបអនុស្សាវរីយ៍ | |
| | សម្រាកអាហារសម្រន់ | |
| ០៩:៣០-០៩:៥០ | - របាយការណ៍នៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ និងកិច្ចប្រជុំត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ស្តីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។ | តំណាងអង្គការ IOM |
| ០៩:៥០-១១:៥០ | - ពិភាក្សាលើគោលបំណងទាំង២៣ ចំណុច របស់កតិកាសញ្ញា<br>- ពិភាក្សាទៅលើគោលបំណងដែលបានជ្រើសរើសពីកិច្ចប្រជុំត្រៀម<br>- ពិភាក្សា និងបោះឆ្នោតជ្រើសរើសគោលបំណង៣/ឬ៤<br>- សង្ខេបលទ្ធផល និងផែនការសកម្មភាព<br>- បិទកម្មវិធីសិក្ខាសាលា | - លោកជំទាវ ជូ ប៊ុនអេង<br>- លោកស្រីKristin Parco |

កម្មវិធីអាចនឹងមានការប្រែប្រួលក្នុងករណីចាំបាច់!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**សមាសភាពអញ្ជើញចូលរួម**
**សិក្ខាសាលាថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំ**
**ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់**
**ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
កម្មវិធីនឹងប្រារព្ធធ្វើនៅថ្ងៃព្រហស្បតិ៍ ១០ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៧ : ៣០ នាទីព្រឹក នៅអគារ S ទីស្តីការក្រសួងមហាផ្ទៃ

| ល.រ | សមាសភាព | ចំនួន | ផ្សេងៗ |
|---|---|---|---|
| **១.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** | | | |
| ១ | លោកជំទាវ ឧ.ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ | ០១រូប | |
| ២ | ឯកឧត្តម ឧ.ឯក ខៀវ ចាន់រ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៣ | ឯកឧត្តម ឧ.ឯក យឹម វិរៈ អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៤ | ឯកឧត្តម ឧ.ឯក ស៊ុន វ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៥ | ឯកឧត្តម ឧ.ឯក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៦ | លោកជំទាវ ឧ.ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៧ | ឯកឧត្តម ឧ.ទោ អ៊ូ ម៉ានីរ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៨ | ឯកឧត្តម ឧ.ទោ លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ៩ | ឯកឧត្តម ឧ.ត្រី តែ សុថារ៉េត អគ្គលេខាធិការរង គ.ជ.ប.ជ | ០១រូប | |
| ១០ | លោក កែប សារឿន ទីប្រឹក្សា គ.ជ.ប.ជ | ០១រូប | |
| ១១ | លោក ឧ.ទោ ហាង ជីវ័ន្ត ប្រធានលេខាធិការដ្ឋាន | ០១រូប | |
| ១២ | លោក ឧ.ទោ ស្រី សាមឌី ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ | ០១រូប | |
| ១៣ | លោក ឧ.ទោ សេក ស៊ីវ៉េត ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ | ០១រូប | |
| ១៤ | លោក ឧ.ទោ កែវ សុវណ្ណារ៉ា ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ | ០១រូប | |
| ១៥ | លោក ឧ.ទោ កែវ ផល្លា ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ | ០១រូប | |
| ១៦ | លោក ឧ.ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ | ០១រូប | |
| ១៧ | លោក ឧ.ត្រី ហែម ប៊ូរ៉ា អនុប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ | ០១រូប | |
| ១៨ | មន្ត្រីបច្ចេកទេស/របាយការណ៍ | ០៤រូប | |
| | សរុប | ២១រូប | |
| **២.ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |

| | | | |
|---|---|---|---|
| ២ | មន្ត្រីជំនាញ | ០៤រូប | |
| | សរុប | ០៥រូប | |
| **៣.ទីស្ដីការគណៈរដ្ឋមន្ត្រី** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់អគ្គនាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **៤.ក្រសួងអប់រំយុវជន និងកីឡា** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់អគ្គនាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០៣រូប | |
| | សរុប | ០៤រូប | |
| **៥.ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់អគ្គនាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **៦.ក្រសួងកិច្ចការនារី** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់អគ្គនាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០៣រូប | |
| | សរុប | ០៤រូប | |
| **៧.ក្រសួងយុត្តិធម៌** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់អគ្គនាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០៣រូប | |
| | សរុប | ០៤រូប | |
| **៨.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់អគ្គនាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **៩.ក្រសួងការពារជាតិ** | | | |
| ១ | ចាត់អញ្ជើញតំណាង | ០៣រូប | |
| | សរុប | ០៣រូប | |
| **១០.ទីចាត់ការការងារព្រំដែន** | | | |
| ១ | ចាត់អញ្ជើញតំណាង | ០៣រូប | |
| | សរុប | ០៣រូប | |
| **១១.កងរាជអាវុធហត្ថលើផ្ទៃប្រទេស** | | | |
| ១ | ចាត់អញ្ជើញតំណាង | ០១រូប | |

| | | | |
|---|---|---|---|
| **១២. ក្រសួងទេសចរណ៍** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **១៣. ក្រសួងសុខាភិបាល** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **១៤. ក្រសួងអភិវឌ្ឍន៍ជនបទ** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **១៥. ក្រសួងព័ត៌មាន** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **១៦. ក្រសួងផែនការ** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **១៧. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០១រូប | |
| | សរុប | ០២រូប | |
| **១៨. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០១រូប | |
| | សរុប | ០២រូប | |
| **១៩. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០១រូប | |
| | សរុប | ០២រូប | |
| **២០. ក្រសួងមុខងារសាធារណៈ** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |

| | | | |
|---|---|---|---|
| ២ | មន្ត្រីជំនាញ | ០១រូប | |
| | សរុប | ០២រូប | |
| **២១.ក្រសួងធម្មការ និងសាសនា** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០១រូប | |
| | សរុប | ០២រូប | |
| **២២.ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់អគ្គនាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០១រូប | |
| | សរុប | ០២រូប | |
| **២៣.អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់ប្រធាននាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **២៤.អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់ប្រធាននាយកដ្ឋាន ) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **២៥.អគ្គនាយកដ្ឋានរដ្ឋបាល** | | | |
| ១ | ថ្នាក់ដឹកនាំ ( ថ្នាក់ប្រធាននាយកដ្ឋាន ) | ០១រូប | |
| **២៦.គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)** | | | |
| ១ | ថ្នាក់អនុប្រធានលេខាធិការដ្ឋាន | ០១រូប | |
| **២៧.គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា** | | | |
| ១ | ចាត់អញ្ជើញតំណាង | ០៣រូប | |
| | សរុប | ០៣រូប | |
| **២៨.ក្រុមប្រឹក្សាអាជ្ញាកណ្តាល** | | | |
| ១ | ចាត់អញ្ជើញតំណាង | ០៣រូប | |
| | សរុប | ០៣រូប | |
| **២៩.នាយកដ្ឋាននគរបាលកណ្តាលព្រំដែនគោក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ** | | | |
| ១ | ថ្នាក់នាយកដ្ឋាន | ០២រូប | |
| | សរុប | ០២រូប | |
| **៣០.នាយកដ្ឋាននគរបាលកណ្តាលព្រំដែនទឹក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ** | | | |
| ១ | ថ្នាក់នាយកដ្ឋាន | ០២រូប | |
| | | ០២រូប | |

| | | | |
|---|---|---|---|
| **៣១.នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន** | | | |
| ១ | ថ្នាក់នាយកដ្ឋាន | ០៣រូប | |
| | សរុប | ០៣រូប | |
| **៣២.នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** | | | |
| ១ | ថ្នាក់នាយកដ្ឋាន | ០៣រូប | |
| | សរុប | ០៣រូប | |
| **៣៣.ការិយាល័យនគរបាលអន្តរជាតិ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ** | | | |
| ១ | ប្រធានការិយាល័យ | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **៣៤.ការិយាល័យកុងស៊ុល និងច្បាប់ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | | | |
| ១ | មន្ត្រីជំនាញ | ០៣រូប | |
| | សរុប | ០៣រូប | |
| **៣៥.សាលាបណ្ឌិត្យសភានគរបាលកម្ពុជា** | | | |
| ១ | ថ្នាក់ដឹកនាំ (ថ្នាក់ប្រធាននាយកដ្ឋាន) | ០១រូប | |
| ២ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០៣រូប | |
| **៣៦.SOM TC** | | | |
| ១ | មន្ត្រីជំនាញ | ០២រូប | |
| | សរុប | ០២រូប | |
| | សរុបរួម | ១១៦ រូប | |
| **៣៧.អង្គការ/ដៃគូរអភិវឌ្ឍន៍** | | | |
| ១ | IOM | ០២រូប | |
| ២ | UN WOMEN | ០២រូប | |
| ៣ | UNAIDS | ០២រូប | |
| ៤ | UNDP | ០២រូប | |
| ៥ | UNICEF | ០២រូប | |
| ៦ | UN-ACT | ០២រូប | |
| ៧ | UNFPA | ០២រូប | |
| ៨ | IJM | ០២រូប | |
| ៩ | National Bank of Cambodia | ០២រូប | |
| ១០ | Samaritans Purse | ០២រូប | |
| ១១ | Caritas | ០២រូប | |
| ១២ | Rathanak International | ០២រូប | |
| ១៣ | CWCC | ០២រូប | |

| | | | |
|---|---|---|---|
| ១៤ | Chab Dai | ០២រូប | |
| ១៥ | LICADHO | ០២រូប | |
| ១៦ | ADHOC | ០២រូប | |
| ១៧ | ACRA | ០២រូប | |
| ១៨ | CAMFEBA | ០២រូប | |
| ១៩ | Asia Foundation | ០២រូប | |
| ២០ | ILO | ០២រូប | |
| ២១ | OHCHR | ០២រូប | |
| ២២ | World Vision | ០២រូប | |
| ២៣ | Winrock International | ០២រូប | |
| ២៤ | ACILS | ០២រូប | |
| ២៥ | MAC | ០២រូប | |
| ២៦ | LSCW | ០២រូប | |
| ២៧ | PLAN | ០២រូប | |
| ២៨ | CAMBODIAN-ACT | ០២រូប | |
| ២៩ | CENTRAL | ០២រូប | |
| | សរុប | ៥៨រូប | |
| **សរុបរួមចំនួន ១៧៣ រូប** | | | |

International Organization for Migration (IOM)
The UN Migration Agency

Global Compact FOR Migration

# សិក្ខាសាលាថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំ ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)

ថ្ងៃព្រហស្បតិ៍ ១០កើត ខែស្រាពណ៍ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០
ទីស្តីការក្រសួងមហាផ្ទៃ អគារ S (ធំ)

កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គឺជាក្របខ័ណ្ឌទូលំទូលាយទីមួយរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តតាមរយៈកិច្ចពិភាក្សា អន្តររដ្ឋាភិបាល ដើម្បីធ្វើឱ្យកិច្ចសហការអន្តរជាតិមានភាពល្អប្រសើរ ក្នុងអភិបាលកិច្ចទេសន្តរប្រវេសន៍ជាសកល និងត្រូវបានឯកភាពគាំទ្រដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដែលប្រារព្ធឡើងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុងញ៉ូយ៉ក ដែលមានសមាជិកចូលរួមចំនួន ១៥២ ប្រទេស។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ នៅទីក្រុងភ្នំពេញ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងមានអ្នកតំណាងចូលរួមជាង ១៧០នាក់ មកពីក្រសួងពាក់ព័ន្ធ ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ស្ថាប័នឯកជន ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការចូលរួមចំណែកត្រៀមធ្វើការអនុម័តទៅលើកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅថ្ងៃទី ១១-១២ ខែធ្នូ ឆ្នាំ២០១៧ នៅទីក្រុងម៉ារ៉ាកិច (នៃប្រទេសម៉ារ៉ុក)។

នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១នោះ បញ្ហាទេសន្តរប្រវេសន៍មិនប្រក្រតី គឺជាប្រធានបទសំខាន់ក្នុងកិច្ចពិភាក្សា ពីព្រោះទេសន្តរប្រវេសន៍មិនប្រក្រតីអាចបង្កភាពងាយរងគ្រោះខ្លាំង ហើយជាបញ្ហាដែលកំពុងកើតឡើងក្នុងចំណោមពលករទេសន្តរប្រវេសន្ត។ បញ្ហាផ្សេងៗទៀត ដូចជាបញ្ហាទេសន្តរប្រវេសន៍ការងារ និងបញ្ហាគ្រប់គ្រងទេសន្តរប្រវេសន៍ ក៏ត្រូវបានលើកឡើងជាចំនុចអទិភាពផងដែរ សម្រាប់ធ្វើការដោះស្រាយ ដើម្បីលើកកំពស់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

ដើម្បីបន្តឆន្ទៈ ចំពោះការអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង IOM បានរៀបចំកិច្ចប្រជុំត្រៀមមួយ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ នៅភ្នំពេញ ជាមួយក្រសួងសំខាន់ៗរបស់រដ្ឋាភិបាលកម្ពុជា។ គោលបំណងក្នុងកិច្ចប្រជុំនេះ គឺដើម្បីរៀបចំត្រៀមសិក្ខាសាលាកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ដោយធ្វើការពិភាក្សាទៅលើគោលបំណងទាំង ២៣ ចំណុច របស់កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ព្រមទាំងធ្វើការជ្រើសរើស និងចាត់អាទិភាពគោលបំណងមួយចំនួន សម្រាប់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងទេសន្តរប្រវេសន៍។

នៅក្នុងកិច្ចប្រជុំត្រៀមនេះ វិស័យចំនួន ០៤ ត្រូវបានកំណត់រកឃើញមានការពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ ហើយ គោលបំណងចំនួន ០៣ ចំណុចត្រូវបានកំណត់ជាគោលបំណងអាទិភាព និងគោលបំណងចំនួន ០៤ ចំណុចទៀតត្រូវបានកំណត់ជាគោលបំណងគួរចាត់អាទិភាពផងដែរ។

វិស័យទាំង ០៤៖

១. ការការពារជនទេសន្តរប្រវេសន្ត — ទាំងជនទេសន្តរប្រវេសន្តប្រក្រតី និងជនទេសន្តរប្រវេសន្តមិនប្រក្រតី (ខ្វះព័ត៌មាន ខ្វះការយល់ដឹង បញ្ហាកេងប្រវ័ញ្ច និងរំលោភបំពាន យុត្តិធម៌ផ្នែកច្បាប់)
២. ការគ្រប់គ្រងទិន្នន័យ — ទាំងជនទេសន្តរប្រវេសន្តប្រក្រតី និងជនទេសន្តរប្រវេសន្តមិនប្រក្រតី
៣. ការគាំទ្រផ្នែកវិលត្រឡប់ និងសមាហរណកម្ម — គោលនយោបាយ ទិន្នន័យ បញ្ហាការការពារស្ត្រី និងកុមារដែលត្រូវគេជួញដូរ
៤. អត្តសញ្ញាណស្របច្បាប់ — សម្រាប់កូនរបស់ជនទេសន្តរប្រវេសន្តមិនប្រក្រតី ដែលបានកើតនៅក្រៅប្រទេសកម្ពុជា។

គោលបំណងអាទិភាព ចំនួន០៣៖

១. គោលបំណងទី៤៖ ធានាថាជនទេសន្តរប្រវេសន្តមានភស្តុតាងអត្តសញ្ញាណ និងឯកសារគ្រប់គ្រាន់។
២. គោលបំណងទី១១៖ គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា។
៣. គោលបំណងទី២៣៖ ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់។

គោលបំណងអាទិភាពបន្ថែម ចំនួន០៤៖

១. គោលបំណងទី១៖ ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមភេទជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើទិន្នន័យពិត។
២. គោលបំណងទី៧៖ ដោះស្រាយ និងកាត់បន្ថយភាពងាយរងគ្រោះក្នុងដំណើរការទេសន្តរប្រវេសន៍។
៣. គោលបំណងទី១២៖ ពង្រឹងឲ្យបាន និងត្រៀមទុកជាមុន នូវនីតិវិធីទេសន្តរប្រវេសន៍ សម្រាប់ការត្រួតពិនិត្យដោយសមស្រប ការប៉ាន់ប្រមាណបញ្ហា និងការបញ្ជូន។
៤. គោលបំណងទី២០៖ ធ្វើឲ្យប្រសើរឡើងនូវការបញ្ជូន ឬការផ្ទេរប្រាក់ដែលឆាប់រហ័ស មានសុវត្ថិភាព តម្លៃទាប និងដាក់បញ្ចូលហិរញ្ញវត្ថុរបស់ជនទេសន្តរប្រវេសន្ត។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ នឹងរៀបចំឡើងនៅភ្នំពេញ នៅសាលប្រជុំអគារ 'ទ' ទីស្ដីការក្រសួងមហាផ្ទៃ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០។ សិក្ខាសាលានេះនឹងធ្វើការពិនិត្យ ពិភាក្សា និងសម្រេចជ្រើសរើសគោលបំណងអាទិភាព ដោយផ្អែកទៅលើតួនាទីស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ។ នៅចុងបញ្ចប់នៃសិក្ខាសាលានេះ តំណាងចូលរួមទាំងអស់នឹងពាំនាំគោលបំណងអាទិភាពទាំងអស់ យកទៅពិភាក្សា និងបញ្ចូលទៅក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រតាមស្ថាប័នរៀងៗខ្លួន។ សិក្ខាសាលាមួយទៀតនឹងត្រូវរៀបចំឡើង ដើម្បីធ្វើបទបង្ហាញ និងពិភាក្សាទៅលើភាពរីកចំរើននៃការអនុវត្តគោលបំណងនៃកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់។

## គោលបំណងទាំង២៣ របស់កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

(១) ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមភេទជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង

(២) កាត់បន្ថយកត្តាអវិជ្ជមាននិងកត្តារចនាសម្ព័ន្ធដែល បង្ខំឲ្យ មនុស្សចាកចេញពីប្រទេសដើម

(៣) ផ្តល់ព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលានៅគ្រប់ដំណាក់កាលនៃទេសន្តរប្រវេសន៍

(៤) ធានាថាជនទេសន្តរប្រវេសន្តទាំងអស់មានភស្តុតាងអត្តសញ្ញាណ និងឯកសារគ្រប់គ្រាន់

(៥) លើកកម្ពស់ភាពអាចរកបាននិងភាពបត់បែននៃដំណើរទេសន្តរប្រវេសន៍ជាប្រចាំ

(៦) សម្របសម្រួលការជ្រើសរើសដោយសមរម្យនិងប្រកបដោយក្រមសីលធម៌ ព្រមទាំងមានលក្ខខណ្ឌផ្តល់កិច្ចការពារដែលធានាបាននូវការងារសមរម្យ

(៧) ដោះស្រាយ និងកាត់បន្ថយភាពងាយរងគ្រោះក្នុងការធ្វើទេសន្តរប្រវេសន៍

(៨) ជួយសង្គ្រោះជីវិតនិងបង្កើតកិច្ចសម្របសម្រួលសហប្រតិបត្តិការអន្តរជាតិចំពោះជនទេសន្តរប្រវេសន្តដែលបាត់ខ្លួន

(៩) ពង្រឹងការឆ្លើយតបឆ្លងប្រទេសចំពោះការរត់ពន្ធជនទេសន្តរប្រវេសន្ត

(១០) បង្ការ ប្រយុទ្ធប្រឆាំង និងលុបបំបាត់ការជួញដូរមនុស្សក្នុងបរិបទអន្តោប្រវេសន៍អន្តរជាតិ

(១១) គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា

(១២) ពង្រឹងភាពជាក់លាក់ និងការប៉ាន់ប្រមាណដំណើរការទេសន្តរប្រវេសន៍ ដើម្បីការត្រួតពិនិត្យ វាយតម្លៃ និងការបញ្ជូនសមស្រប

(១៣) ប្រើការឃុំឃាំងជនទេសន្តរប្រវេសន្តគ្រាន់តែជាវិធានការចុងក្រោយ ហើយធ្វើការឆ្ពោះទៅរកជម្រើសផ្សេង

(១៤) ពង្រឹងការការពារ ការផ្តល់ជំនួយ និងកិច្ចសហប្រតិបត្តិការតាមរយៈស្ថានកុងស៊ុលពេញមួយវដ្តនៃទេសន្តរប្រវេសន៍

(១៥) ផ្តល់លទ្ធភាពទទួលបានសេវាកម្មមូលដ្ឋានសម្រាប់ជនទេសន្តរប្រវេសន្ត

(១៦) ផ្តល់សិទ្ធិអំណាចដល់ជនទេសន្តរប្រវេសន្ត និងសង្គមអោយមានការយល់ដឹងពេញលេញ និងការរួបរួមគ្នាក្នុងសង្គម

(១៧) លុបបំបាត់រាល់ទម្រង់នៃការរើសអើង និងលើកកម្ពស់ទំនាក់ទំនងជាសាធារណៈផ្អែកលើភស្តុតាង ដើម្បីបង្ហាញពីការយល់ឃើញនៃទេសន្តរប្រវេសន៍

(១៨) វិនិយោគលើការអភិវឌ្ឍជំនាញ និងសម្របសម្រួលដល់ការទទួលស្គាល់ជំនាញគុណវុឌ្ឍិ និងសមត្ថភាពដោយភាគីទាំងសងខាង

(១៩) បង្កើតលក្ខខណ្ឌសម្រាប់ជនទេសន្តរប្រវេសន្ត និងជនចំណូលស្រុក ដើម្បីចូលរួមចំណែកយ៉ាងពេញលេញដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅគ្រប់ប្រទេស

(២០) ធ្វើឲ្យប្រសើរឡើងនូវការបញ្ជូន ឬការផ្ទេរប្រាក់ដែលឆាប់រហ័ស មានសុវត្ថិភាព តម្លៃទាប និងដាក់បញ្ចូលហិរញ្ញវត្ថុរបស់ជនទេសន្តរប្រវេសន្ត

(២១) សហប្រតិបត្តិការសម្របសម្រួលការវិលត្រឡប់មកវិញប្រកបដោយសុវត្ថិភាពនិងភាពថ្លៃថ្នូរ ក៏ដូចជាការធ្វើសមាហរណកម្មឡើងវិញប្រកបដោយចីរភាព

(២២) បង្កើតយន្តការសំរាប់យថាភាពនៃសិទ្ធិទទួលបានសន្តិសុខសង្គមនិងផលចំណេញដែលទទួលបាន

(២៣) ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកលស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

**The 23 Objectives of the Global Compact for Safe, Orderly and Regular Migration**

1) Collect and utilize accurate and disaggregated data as a basis for evidence-based policies
2) Minimize the adverse drivers and structural factors that compel people to leave their country of origin
3) Provide accurate and timely information at all stages of migration
4) Ensure that all migrants have proof of legal identity and adequate documentation
5) Enhance availability and flexibility of pathways for regular migration
6) Facilitate fair and ethical recruitment and safeguard conditions that ensure decent work
7) Address and reduce vulnerabilities in migration
8) Save lives and establish coordinated international efforts on missing migrants
9) Strengthen the transnational response to smuggling of migrants
10) Prevent, combat and eradicate trafficking in persons in the context of international migration
11) Manage borders in an integrated, secure and coordinated manner
12) Strengthen certainty and predictability in migration procedures for appropriate screening, assessment and referral
13) Use migration detention only as a measure of last resort and work towards alternatives
14) Enhance consular protection, assistance and cooperation throughout the migration cycle
15) Provide access to basic services for migrants
16) Empower migrants and societies to realize full inclusion and social cohesion
17) Eliminate all forms of discrimination and promote evidence-based public discourse to shape perceptions of migration
18) Invest in skills development and facilitate mutual recognition of skills, qualifications and competences
19) Create conditions for migrants and diasporas to fully contribute to sustainable development in all countries
20) Promote faster, safer and cheaper transfer of remittances and foster financial inclusion of migrants
21) Cooperate in facilitating safe and dignified return and readmission, as well as sustainable reintegration
22) Establish mechanisms for the portability of social security entitlements and earned benefits
23) Strengthen international cooperation and global partnerships for safe, orderly and regular migration